ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

# របាយការណ៍ប្រចាំឆ្នាំ២០១១
# និង
# ទិសដៅការងារឆ្នាំ២០១២



ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ធនាគារជាតិ នៃ កម្ពុជា
NATIONAL BANK OF CAMBODIA

# របាយការណ៍ប្រចាំឆ្នាំ២០១១
# និង
# ទិសដៅការងារឆ្នាំ២០១២

# អារម្ភកថា

នៅក្នុងឆ្នាំ២០១១ នេះ សេដ្ឋកិច្ចពិភពលោកទទួលរងសម្ពាធមួយថ្មី ដែលនាំឲ្យសន្ទុះកំណើនមានកម្រិតទាបជាងឆ្នាំ២០១០ ដោយសារវិបត្តិបំណុលសាធារណៈនៅតំបន់អឺរ៉ុបមានសភាពធ្ងន់ធ្ងរ និងក្លាយជាបញ្ហាប្រឈមចំពោះទស្សនៈវិស័យសេដ្ឋកិច្ចពិភពលោក ។ ទន្ទឹមនោះ បញ្ហាអតុល្យភាពសេដ្ឋកិច្ចសកលក៏ពុំទាន់មានដំណោះស្រាយសមស្រប ខណៈប្រទេសអភិវឌ្ឍន៍មួយចំនួន នៅមានអត្រានិកម្មភាពខ្ពស់ ជំនឿទុកចិត្តរបស់អ្នកវិនិយោគនិងអ្នកប្រើប្រាស់នៅទាប ហើយការស្តារឡើងវិញពីគ្រោះធម្មជាតិពុំទាន់បានបញ្ចប់ជាស្ថាពរ ។

ការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF)[១] បានបង្ហាញថា កំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះពី ៥,១% នៅឆ្នាំ២០១០ មក ៤% នៅឆ្នាំ២០១១ នេះ ក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ដូចជាសហរដ្ឋអាមេរិកមានអត្រាកំណើន ១,៥% និងអឺរ៉ុប ១,៦% ខណៈដែលសេដ្ឋកិច្ចតំបន់អាស៊ីមានមូលដ្ឋានរឹងមាំក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចពិភពលោក ក្នុងនោះ ប្រទេសចិនមានអត្រាកំណើន ៩,៥% ឥណ្ឌា ៧,៨% និង អាស៊ានធំប្រាំ ៥,៣% ទោះបីសេដ្ឋកិច្ចជប៉ុនមានកំណើន -0,៥% ក៏ដោយ ។

ចំពោះប្រទេសកម្ពុជា ឆ្នាំ២០១១ បានបង្ហាញលទ្ធផលល្អគួរកត់សម្គាល់ ដោយស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរក្សាស្ថិរភាពយ៉ាងល្អប្រសើរ ទោះបីជាមានផលប៉ះពាល់ពីគ្រោះទឹកជំនន់នៅតំបន់ខ្លះក្តី ។ ស្ថិតក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រង និងការអនុវត្តនយោបាយសារពើពន្ធនិងរូបិយវត្ថុសមស្របរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ៦,៩% ដែលទ្រទ្រង់ដោយការរីកចម្រើននៃវិស័យកសិកម្ម ៣,៣% ឧស្សាហកម្ម ១៤,៣% (វិស័យកាត់ដេរ ២០,២%) និងសេវាកម្ម ៥% ។

ប្រតិបត្តិការជញ្ជីងទូទាត់របស់កម្ពុជាមានស្ថានភាពប្រសើរជាងឆ្នាំមុន ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃឱនភាពសមតុល្យគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ពី ១0% មក ៨% នៃផសស ខណៈសមតុល្យរួមមានអតិរេក ១,៧% នៃផសស ។ ទុនបម្រុងអន្តរជាតិដុលបានកើនឡើងដល់ជាង ៣ ពាន់លានដុល្លារអាមេរិក ដែលអាចធានាការនាំចូលបាន ៤,៩ ខែ ។ ធនាគារជាតិនៃកម្ពុជាបានបន្តគ្រប់គ្រងទុនបម្រុងអន្តរជាតិដោយប្រុងប្រយ័ត្ន ផ្អែកលើគោលការណ៍ ទី១-សុវត្ថិភាព ទី២-សន្ទនីយភាព និងទី៣-ចំណូល ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានខិតខំរក្សាស្ថិរភាពថ្លៃតាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្ន សំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ។ សម្ពាធអតិផរណាក្នុងឆ្នាំ២០១១ ស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ដោយមានអត្រាមធ្យមប្រចាំឆ្នាំត្រឹម ៥,៥% ។ គិតតាមអត្រាទិញទីផ្សារមធ្យមប្រចាំឆ្នាំ ប្រាក់រៀលបានឡើងថ្លៃ ៣,២% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការកើនឡើងនៃតម្រូវការប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ច និងកំណើនលំហូរចូលនៃដើមទុនមកក្នុងប្រទេស ក្នុងនោះ វិនិយោគផ្ទាល់បរទេសមានទំហំប្រមាណ ៦៧៧ លានដុល្លារអាមេរិក ។

[១] World Economic Outlook (IMF) in September 2011

ជារួម ក្នុងអំឡុងមួយទសវត្សរ៍នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពល្អប្រសើរ ដែលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារ និងសេដ្ឋកិច្ចជាតិ ។

បច្ចុប្បន្ន វិស័យធនាគារនៅកម្ពុជាមានការអភិវឌ្ឍជាលំដាប់ ទាំងវិសាលភាព និងទំហំប្រតិបត្តិការ ។ នៅឆ្នាំ២០១១ នេះ សាខាធនាគារបរទេសខ្នាតអន្តរជាតិចំនួន ៤ បានទទួលអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារនៅកម្ពុជា ។ បណ្តាញសាខារបស់គ្រឹះស្ថានធនាគារបានកើនឡើងពី ៣៦១ នៅឆ្នាំ ២០១០ ដល់ ៤០៧ នៅឆ្នាំ២០១១ ។ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ និងឥណទានចំពោះវិស័យឯកជនបានកើនឡើង ២១,៤% និង ៣១,៧% រៀងគ្នា ធៀបឆ្នាំ២០១០ ហើយវិស័យដែលមានកំណើនឥណទានខ្ពស់ជាងគេគឺកសិកម្ម ៦៤% ឧស្សាហកម្ម ៣៧% និងសំណង់ ៣៩% ។ លទ្ធផលនេះបានបង្ហាញនូវការយកចិត្តទុកដាក់នៃវិស័យធនាគារក្នុងការលើកកម្ពស់វិស័យកសិកម្មស្របតាមការចង្អុលទិសដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ។ គ្រឹះស្ថានធនាគារមានសុខភាពរឹងមាំ ដែលឆ្លុះបញ្ចាំងដោយអនុបាតសាធនភាពជាមធ្យមក្នុងកម្រិតប្រមាណ ២៨,៦% អនុបាតសាច់ប្រាក់ងាយស្រួល (សន្ទនីយភាព) ៨៧% និងអនុបាតឥណទានមិនដំណើរការ ៣,៣% ។ កម្មវិធីបង្កើនដើមទុនអប្បបរមាចំពោះគ្រឹះស្ថានធនាគារក៏ត្រូវបានបញ្ចប់ដោយជោគជ័យ ។

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារយ៉ាងយកចិត្តទុកដាក់ សំដៅជំរុញប្រតិបត្តិការធនាគារឲ្យប្រព្រឹត្តទៅដោយរលូន មានប្រសិទ្ធភាព និងសុវត្ថិភាព តាមរយៈការលើកកម្ពស់ការត្រួតពិនិត្យ និងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិនានា ។ ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏មានការរីកចម្រើនជាលំដាប់ និងមានបណ្តាញសេវាទូលំទូលាយដល់ជនបទ ។ វិស័យនេះបានដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ ឥណទានមីក្រូហិរញ្ញវត្ថុបានកើនដល់ ២.២៩៧ ពាន់លានរៀល មានកំណើន ៣៣% ធៀបនឹងឆ្នាំកន្លងទៅ ខណៈចំនួនអតិថិជនបានកើនដល់ជាង១លាននាក់ ។

ធនាគារជាតិនៃកម្ពុជាបានបន្តចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២របស់រាជរដ្ឋាភិបាល តាមរយៈការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាធនាគារកណ្តាលជូនក្រសួងស្ថាប័នរដ្ឋ និងពង្រីកការបំពាក់ប្រព័ន្ធធនាគារស្នូលនៅតាមសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត ។

លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធជាតិទូទាត់សងប្រាក់ដែលអាចទូទាត់ និងជាត់ទាត់ទាំងមូលប្បទានបត្រ និងឧបករណ៍ទូទាត់ផ្សេងៗទៀតជាលក្ខណៈមជ្ឈការដើម្បីសម្រួលដល់ការទូទាត់ឲ្យកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព ។ ប្រព័ន្ធទូទាត់នេះនឹងត្រូវដាក់ឲ្យដំណើរការនៅក្នុងអំឡុងឆ្នាំ២០១២ ខាងមុខ ។ សេចក្តីព្រាងច្បាប់ស្តីពី "ប្រព័ន្ធជាតិទូទាត់សងប្រាក់" ត្រូវបានរៀបចំឡើងដោយមានកិច្ចសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ដើម្បីជាមូលដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធទូទាត់ ។

ក្រោមជំនួយបច្ចេកទេសរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ និងដោយមានការគាំទ្រពីធនាគារជាតិនៃកម្ពុជា ការិយាល័យព័ត៌មានឥណទានត្រូវបានបង្កើតឡើងនាដំណាច់ឆ្នាំនេះ ដែលជាសហកម្មសិទ្ធិនៃសមាគមធនាគារកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងអ្នកផ្តល់សេវាបច្ចេកវិទ្យាព័ត៌មាន ។

ដោយឡែក ការរៀបចំបង្កើតទីផ្សារអន្តរធនាគារនិងរូបិយវត្ថុកំពុងដំណើរការជាលំដាប់ និងសម្រេចបាននូវវឌ្ឍនភាពជាជំហានៗ ដូចជា ការរៀបចំកិច្ចបញ្ជិកាគណនេយ្យសម្រាប់ប្រតិបត្តិការទិញ-លក់-រក្សាមូលបត្រប្រព័ន្ធព័ត៌មានវិទ្យា និងនីតិវិធីប្រតិបត្តិការផ្សេងៗសម្រាប់ការចេញផ្សាយមូលបត្រធនាគារកណ្តាលក្នុងដំណាក់កាលដែលមិនទាន់មានមូលបត្ររដ្ឋសម្រាប់ជំរុញទីផ្សារនេះ ។

ចំពោះការងារប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) បានចូលរួមជាមួយស្ថាប័នជាតិ និងអន្តរជាតិ ពិសេស ក្រសួង-ស្ថាប័នរបស់រាជរដ្ឋាភិបាល និងក្រុមប្រទេសអាស៊ីប៉ាស៊ីហ្វិកស្តីពីការសម្អាតប្រាក់ ក្នុងការតាមដានសកម្មភាពពាក់ព័ន្ធផ្សេងៗ ហើយនៅក្នុងឆ្នាំ២០១១នេះ ស.ហ.ក ក៏បានចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការស្តីពី ការផ្លាស់ប្តូរព័ត៌មានជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជប៉ុនផងដែរ ។

សមិទ្ធផលដ៏សំខាន់មួយនៅក្នុងឆ្នាំ២០១១ នេះ ចំពោះវិស័យហិរញ្ញវត្ថុ គឺការអនុម័តរបស់រាជរដ្ឋាភិបាល កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ លើឯកសារ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០" ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មពី "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០០៦-២០១៥" ។ ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាងធនាគារជាតិនៃកម្ពុជា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ព្រមទាំងគណៈកម្មការមូលបត្រកម្ពុជា និងក្រោមជំនួយបច្ចេកទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីជាមូលដ្ឋានក្នុងការបន្តអភិវឌ្ឍវិស័យហិរញ្ញវត្ថុកម្ពុជា ស្របតាមការរីកចម្រើននៃសេដ្ឋកិច្ចជាតិនិងតំបន់ ។

ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី៤ថ្នាក់ទេសាភិបាលរងអាស៊ានផ្នែកសមាហរណកម្មវិស័យហិរញ្ញវត្ថុ កិច្ចប្រជុំប្រចាំឆ្នាំថ្នាក់នាយកប្រតិបត្តិស៊ាសិនលើកទី៩ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) លើកទី១៨ ។

សរុបមក សមិទ្ធផលដ៏ល្អប្រសើរដែលសម្រេចបាននេះ កើតឡើងដោយសារការខិតខំប្រកបដោយការប្តេជ្ញាចិត្តរបស់មន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ និងការគាំទ្រយ៉ាងមុតមាំរបស់ក្រុមប្រឹក្សាភិបាលនៃធនាគារជាតិនៃកម្ពុជា ជាពិសេសកិច្ចសហប្រតិបត្តិការល្អពីក្រសួង-ស្ថាប័នរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ។ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅដល់ក្រុមប្រឹក្សាភិបាល មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជា និងគ្រប់ស្ថាប័នពាក់ព័ន្ធព្រមទាំងដៃគូអភិវឌ្ឍន៍ដែលបានចូលរួមវិភាគទានដ៏មានតម្លៃក្នុងការសម្រេចបាននូវជោគជ័យទាំងអស់នេះ ។

**ទេសាភិបាល**

# មាតិកា

* * *


ក- របាយការណ៍ឆ្នាំ២០១១ ........ ១

សេចក្តីផ្តើម ........ ២

I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា ........ ៣

១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល ........ ៣

១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា ........ ៣

១.២- ស្ថានភាពអត្រាប្តូរប្រាក់ ........ ៥

១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ........ ៥

១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន ........ ៧

១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន ........ ៧

២- ការវិវត្តរូបិយវត្ថុ ........ ៨

២.១- ការផ្គត់ផ្គង់រូបិយវត្ថុ ........ ៩

២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ ........ ៩

២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា ........ ១០

២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ ........ ១០

២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ ........ ១១

៣- ជញ្ជីងទូទាត់ ........ ១២

៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) ........ ១៣

៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ ........ ១៤

៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ........ ១៦

៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ ........ ១៦

៤.២- អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់ ........ ១៦

៤.៣- ការងារប្រតិវេទន៍ និងការផ្តល់អាជ្ញាប័ណ្ណនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ ..... ១៧

៤.៣.១- ការងារប្រតិវេទន៍ ..... ១៧

៤.៣.២- ការផ្តល់អាជ្ញាប័ណ្ណនាំចេញ-ចូល លោហធាតុនិងត្បូងថ្មមានតម្លៃ ..... ១៧

៥- សម្ព័ន្ធការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ..... ១៧

៥.១- ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ..... ១៨

៥.១.១- ការត្រួតពិនិត្យលើឯកសារ ..... ១៨

៥.១.២- ការត្រួតពិនិត្យដល់ទីកន្លែង ..... ១៨

៥.១.៣- ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ..... ១៨

៥.២- ការងារនីតិកម្ម ..... ១៩

៥.៣- ការងារផ្តល់អាជ្ញាប័ណ្ណ ..... ១៩

៥.៤- ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក) ..... ២០

៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល ..... ២០

៦.១- សេវាគ្រប់គ្រងគណនី ..... ២០

៦.១.១- សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ ..... ២០

៦.១.២- សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ..... ២០

៦.២- សេវាផ្ទេរប្រាក់ក្នុងប្រទេស ..... ២០

៦.៣- សេវាផាត់ទាត់មូលប្បទានបត្រ ..... ២១

៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល ..... ២១

៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក ..... ២១

៦.៤- ការងារឥណទាន ..... ២១

៦.៥- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល ..... ២១

៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ ..... ២៣

៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់ ..... ២៤

៩- ការងារព័ត៌មានវិទ្យា ..... ២៤
II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា ..... ២៥
១- សកម្មភាពក្រុមប្រឹក្សាភិបាល ..... ២៥
២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស ..... ២៦
២.១- ស្ថិតិមន្ត្រីបុគ្គលិក ..... ២៦
២.២- ការងារបណ្តុះបណ្តាល ..... ២៦
៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ..... ២៧
៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា ..... ២៧
III- ទំនាក់ទំនងអន្តរជាតិ ..... ២៨
១- ទំនាក់ទំនងពហុភាគី ..... ២៨
១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ ..... ២៨
១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី ..... ២៨
១.៣- ទំនាក់ទំនងជាមួយអាស៊ាន និងអាស៊ាន + ៣ ..... ២៩
១.៤- ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ (ស៊ាសិន - SEACEN) ..... ៣០
១.៥- ទំនាក់ទំនងជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន - Francophone) ..... ៣០
២- ទំនាក់ទំនងទ្វេភាគី ..... ៣០
សន្និដ្ឋាន ..... ៣២
ខ- ទិសដៅការងារឆ្នាំ២០១២ ..... ៣៤
១- ការងាររូបិយវត្ថុ ..... ៣៥
២- ការងារប្តូរប្រាក់ និងការគ្រប់គ្រងទុនបម្រុងអន្តរជាតិ ..... ៣៥
៣- ការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់ ..... ៣៥
៤- ការងារត្រួតពិនិត្យ ..... ៣៥

៥- ការងារប្រតិបត្តិការ ........ ៣៦

៦- ការងារបោះផ្សាយ និងឃ្លាំងបេឡា ........ ៣៦

៧- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច ........ ៣៦

៨- ការងារព័ត៌មានវិទ្យា ........ ៣៦

៩- ការងារបណ្តុះបណ្តាល ........ ៣៦

១០- សហប្រតិបត្តិការអន្តរជាតិ ........ ៣៧

ឧបសម្ព័ន្ធ ........ ៣៨

ឧបសម្ព័ន្ធ ១ ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា ........ ៣៩

ឧបសម្ព័ន្ធ ២ ការវិវត្តនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងសេវា (ធ្នូ-២០០៧-ធ្នូ-២០១១) ........ ៤០

ឧបសម្ព័ន្ធ ៣ ប្រាក់រៀលធៀបជាមួយរូបិយប័ណ្ណផ្សេងៗ (អត្រាទិញចុងខែ) ........ ៤១

ឧបសម្ព័ន្ធ ៤ ស្ថានភាពរូបិយវត្ថុ (គិតជាពាន់លានរៀល) ........ ៤២

ឧបសម្ព័ន្ធ ៥ ស្ថានភាពរូបិយវត្ថុ (បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ) ........ ៤៣

ឧបសម្ព័ន្ធ ៦ តារាងគណនីវិភាគធនាគារជាតិនៃកម្ពុជា ........ ៤៤

ឧបសម្ព័ន្ធ ៧ តារាងគណនីវិភាគធនាគារពាណិជ្ជ ........ ៤៥

ឧបសម្ព័ន្ធ ៨ ឥណទានតាមប្រភេទជំនួញក្នុងវិស័យសេដ្ឋកិច្ច ........ ៤៦

ឧបសម្ព័ន្ធ ៩ ជញ្ជីងទូទាត់ប្រទេសកម្ពុជា (ឆ្នាំ២០០៨ ដល់ ឆ្នាំ២០១១) ........ ៤៧

# ក- របាយការណ៍ប្រចាំឆ្នាំ២០១១

## សេចក្តីផ្តើម

នៅឆ្នាំ២០១១ សេដ្ឋកិច្ចពិភពលោកពុំទាន់បានចាកផុតពីឥទ្ធិពលនៃវិបត្តិហិរញ្ញវត្ថុដែលបានកើតឡើងនៅឆ្នាំ២០០៨-២០០៩ កន្លងមកនេះទេ ។ ភាពមិនច្បាស់លាស់ក្នុងការដោះស្រាយវិបត្តិបំណុលអឺរ៉ុប នៅតែជាសម្ពាធចំពោះសកម្មភាពសេដ្ឋកិច្ចនិងវិស័យហិរញ្ញវត្ថុនៃបណ្តាប្រទេសអភិវឌ្ឍ ហើយដែលអាចមានផលប៉ះពាល់ចំពោះទស្សនៈវិស័យសេដ្ឋកិច្ចរយៈកាលខ្លីនៃតំបន់អាស៊ីផងដែរ ។

ទោះបីជាស្ថានភាពក្រៅប្រទេសមានលក្ខណៈមិនអំណោយផល ហើយវិស័យកសិកម្មនៅក្នុងប្រទេសក៏ទទួលរងគ្រោះទឹកជំនន់នៅត្រីមាសទី៣នៃឆ្នាំនេះក៏ដោយ ក៏សេដ្ឋកិច្ចកម្ពុជានៅតែបន្តមានកំណើនដល់ ៦,៩% ធៀបនឹងឆ្នាំ២០១០ ដែលមាន ៦%។

សូចនាករម៉ាក្រូសេដ្ឋកិច្ចដទៃទៀតក៏បង្ហាញនូវស្ថិរភាពយ៉ាងប្រសើរដែរ ដោយអត្រាអតិផរណាមធ្យមឆ្នាំលើឆ្នាំក្នុងឆ្នាំ២០១១ ស្មើនឹង ៥,៥% ធៀបនឹង ៤% នៅឆ្នាំ២០១០ ។ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពគួរឲ្យកត់សម្គាល់ និងថែមទាំងបង្ហាញនិន្នាការឡើងថ្លៃក្នុងអំឡុងត្រីមាសចុងក្រោយ ។ ជាក់ស្តែង គិតតាមអត្រាទិញទីផ្សារចុងគ្រាប្រាក់រៀលបានចុះថ្លៃប្រមាណ ០,២% នាដំណាច់ខែធ្នូ ឆ្នាំ២០១១ ធៀបនឹងឆ្នាំ២០១០ ។ ការអនុវត្តគោលនយោបាយរូបិយវត្ថុក្នុងបរិស្ថាននៃដុល្លារូបនីយកម្មខ្ពស់គឺជាបញ្ហាប្រឈមសម្រាប់ធនាគារជាតិនៃកម្ពុជា ។ ក្នុងបរិការណ៍នេះ គោលនយោបាយប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង គឺជាឧបករណ៍ដ៏សំខាន់ក្នុងការរក្សាស្ថិរភាពថ្លៃ ហើយដូចនេះរួមចំណែកចំពោះស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ។

ទន្ទឹមនឹងការទទួលបានលទ្ធផលល្អក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច វិស័យធនាគារក៏មានការរីកចម្រើនផងដែរក្នុងឆ្នាំ២០១១ នេះ ដែលឆ្លុះបញ្ចាំងតាមរយៈការរក្សាបាននូវស្ថិរភាពគួរកត់សម្គាល់ ការបន្តកើនឡើងនៃអន្តរការិយកម្មធនាគារបន្ទាប់ពីបានថមថយសន្ទុះនៅឆ្នាំ២០០៩ ការផ្តល់នូវសេវាហិរញ្ញវត្ថុថ្មីៗចំពោះអ្នកប្រើប្រាស់និងអាជីវករឯកជន និងការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗនៅក្នុងវិស័យហិរញ្ញវត្ថុ ។ លើសពីនេះ ដើម្បីឆ្លើយតបទៅនឹងការវិវត្តដ៏លឿននៃប្រព័ន្ធហិរញ្ញវត្ថុក្នុងប្រទេស ធនាគារជាតិនៃកម្ពុជាបន្តពង្រឹងសមត្ថភាពរបស់ខ្លួនបន្ថែមទៀតក្នុងការគ្រប់គ្រងនិងត្រួតពិនិត្យប្រព័ន្ធធនាគារ ព្រមទាំងជំរុញឲ្យគ្រឹះស្ថានធនាគារមានក្របខ័ណ្ឌអភិបាលកិច្ចនិងការគ្រប់គ្រងហានិភ័យសមស្រប ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានបង្កើនទំនាក់ទំនងយ៉ាងសកម្មជាមួយបណ្តាធនាគារកណ្តាលនៃប្រទេសជាច្រើនក្នុងតំបន់ សំដៅអនុវត្តកិច្ចសហការផ្នែកត្រួតពិនិត្យរួមទាំងការចែករំលែកព័ត៌មាន និងបទពិសោធន៍រវាងគ្នាទៅវិញទៅមក ។

ក្នុងស្មារតីពង្រឹងស្ថិរភាពប្រព័ន្ធធនាគារ ធនាគារជាតិនៃកម្ពុជាបានអនុវត្តបញ្ចប់ដោយរលូននូវកម្មវិធីបង្កើនដើមទុនអប្បបរមាសម្រាប់គ្រឹះស្ថានធនាគារ និងបានពង្រឹងបទប្បញ្ញត្តិប្រុងប្រយ័ត្នមួយចំនួនទៀតផង ។ ការិយាល័យឥណទានត្រូវបានបង្កើតឡើង ហើយនឹងដំណើរការនៅពេលឆាប់ៗនេះ ។ ដោយឡែក ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់ និងចាំបាច់ត្រូវពង្រឹងសមត្ថភាពត្រួតពិនិត្យ និងរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិប្រុងប្រយ័ត្នផ្សេងៗបន្ថែមទៀត ដើម្បីត្រៀមលក្ខណៈសមស្របសម្រាប់ដំណើរការទីផ្សារទុននាពេលខាងមុខ ។

## I- ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងប្រតិបត្តិការធនាគារជាតិនៃកម្ពុជា

### ១- ស្ថានភាពថ្លៃ និងតម្លៃប្រាក់រៀល

#### ១.១- ការវិវត្តថ្លៃទំនិញ និងអតិផរណា

ថ្លៃទំនិញទូទៅនៅលើទីផ្សារក្នុងស្រុកនៃប្រទេសកម្ពុជាបានរងសម្ពាធខ្ពស់ជាងឆ្នាំកន្លងទៅ ។ កត្តាជាច្រើនរួមទាំងគ្រោះទឹកជំនន់ដែលធ្វើឲ្យប៉ះពាល់ដល់ការផ្គត់ផ្គង់ក្នុងស្រុក បានរួមចំណែកដល់ការកើនឡើងនៃអត្រាអតិផរណានាឆ្នាំនេះ ។ ចំពោះកត្តាក្រៅប្រទេស កម្រិតអតិផរណាខ្ពស់នៃបណ្តាប្រទេសនានាក្នុងតំបន់ដែលជាដៃគូពាណិជ្ជកម្មសំខាន់ៗជាមួយប្រទេសកម្ពុជា និងការឡើងថ្លៃនៃប្រេងឥន្ធនៈ និងស្បៀងអាហារនៅលើទីផ្សារពិភពលោក ក៏មានឥទ្ធិពលគួរឲ្យកត់សម្គាល់ផងដែរមកលើថ្លៃទំនិញនិងសេវាក្នុងស្រុក ។

ប្រឈមនឹងបញ្ហាខាងលើនេះ ធនាគារជាតិនៃកម្ពុជាបានអនុវត្តគោលនយោបាយរូបិយវត្ថុទន់ភ្លន់ប្រុងប្រយ័ត្ន និងសមស្រប ដើម្បីបន្ថយសម្ពាធអតិផរណា ។ ការរក្សាស្ថិរភាពប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកបានក្លាយជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការសម្រេចគោលដៅរូបិយវត្ថុនៅក្នុងបរិបទនៃដុល្លារូបនីយកម្មខ្ពស់ក្នុងសេដ្ឋកិច្ចកម្ពុជា ។ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំមានកម្រិត ៥,៥% នៅឆ្នាំ២០១១នេះ ធៀបនឹង ៤% នាឆ្នាំ២០១០ ។

ក្រាហ្វស្ថិតិ ១ : **អតិផរណាឆ្នាំលើឆ្នាំ**




ពិនិត្យលើបម្រែបម្រួលឆ្នាំលើឆ្នាំឃើញថា នាដំណាច់ឆ្នាំ២០១១ នេះ អតិផរណាមានអត្រា ៤,៩% ខ្ពស់ជាងឆ្នាំ២០១០ ដែលមានកម្រិតត្រឹម ៣,១% និងទាបជាងឆ្នាំ២០០៩ ដែលមានអត្រា ៥,៣% ។

ចលនាកើនឡើងនៃអត្រាអតិផរណាឆ្នាំលើឆ្នាំ ឆ្លុះបញ្ចាំងដោយការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមទំនិញមួយចំនួន រួមមានក្រុម ទំនិញនិងសេវាកម្មផ្សេងៗ ៨,៥% ភោជនីយដ្ឋាន ៧,៥% ការដឹកជញ្ជូន ៦,៣% ម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ៦,២ % សម្លៀកបំពាក់និងស្បែកជើង ៣,០% គ្រឿងសង្ហារិម សម្ភារៈប្រើប្រាស់គ្រួសារនិងការថែទាំផ្ទះជាប្រចាំ ២,២% ផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត ២,១% ការសិក្សា ១,៨% និងភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ ១,៥% ។ ទន្ទឹមនោះ សន្ទស្សន៍ថ្លៃក្រុមទំនិញដែលបានថយចុះ រួមមានក្រុម សុខាភិបាល ១,៤% ការកម្សាន្តនិងវប្បធម៌ ១,២% និងគមនាគមន៍ ០,៥% ។

ក្រាហ្វិក ២ : **ក្រុមមុខទំនិញដែលឡើងថ្លៃខ្លាំងជាងគេក្នុងឆ្នាំ២០១១** (ឆ្នាំលើឆ្នាំ)




ការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមម្ហូបអាហារនិងភេសជ្ជៈមិនមែនជាតិស្រវឹង ដែលជាក្រុមមានមេគុណខ្ពស់ជាងគេបំផុតនោះ ជាចម្បងបណ្តាលមកពីការឡើងថ្លៃសាច់ជ្រូក ២២,៧% សាច់គោ ១៦,២% ប្រេងឆានិងខ្លាញ់ ១០,៩% បន្លែ ៩,៥% សាច់ទា ៧,៩% សាច់កែច្នៃក្នុងស្រុក ៦,៦% និងផ្លែឈើ ៣,៦% ។ ដោយឡែក ការកើនឡើងនៃសន្ទស្សន៍ថ្លៃក្រុមការដឹកជញ្ជូនដែលរាប់បញ្ចូលទាំងថ្លៃប្រេងឥន្ធនៈផងនោះ គឺជាលទ្ធផលនៃការឡើងថ្លៃប្រេងម៉ាស៊ូត ១៥,៤% ប្រេងសាំង ១១,0% និងសេវាកម្មដឹកជញ្ជូន ៦,១% ។

ក្រាហ្វិក ៣ : **ការរួមចំណែកក្នុងអតិផរណា** (ឆ្នាំលើឆ្នាំ)




កត្តាមួយចំនួនដែលបានរួមចំណែកក្នុងអតិផរណារួមប្រចាំឆ្នាំ ៤,៩% នាឆ្នាំ២០១១នេះ រួមមានក្រុមម្ហូបអាហារនិងភេសជ្ជៈពុំមានជាតិស្រវឹង ២,៨% (ត្រូវនឹងសមាមាត្រ ៥៦,២% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមដឹកជញ្ជូន 0,៨% (ត្រូវនឹងសមាមាត្រ ១៥,៨% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមភោជនីយដ្ឋាន 0,៤% (ត្រូវនឹងសមាមាត្រ ៩,0% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមផ្ទះសម្បែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត 0,៤% (ត្រូវនឹងសមាមាត្រ ៧,៤% នៃអត្រាអតិផរណាប្រចាំឆ្នាំ) ក្រុមទំនិញនិងសេវាផ្សេងៗ 0,២% (ត្រូវនឹងសមាមាត្រ ៤,0% នៃអត្រាអតិផរណាប្រចាំឆ្នាំ) និង ៧ក្រុមទៀត ដែលនៅសល់បានចូលរួមចំណែកតែ 0,១% ប៉ុណ្ណោះ (ត្រូវនឹងសមាមាត្រ១,៧% នៃអត្រាអតិផរណាប្រចាំឆ្នាំ)។

ក្រាហ្វស្ថិតិ ៤ : **អតិផរណាមិនរាប់បញ្ចូលក្រុមទំនិញសំខាន់ៗ** (ឆ្នាំលើឆ្នាំ)




ខណៈដែលអតិផរណារួមមានកម្រិត ៤,៩% អត្រាអតិផរណាមិនរាប់បញ្ចូលក្រុមម្ហូបអាហារ មានកម្រិតត្រឹម ៣,៧% ប៉ុណ្ណោះ ដែលបញ្ជាក់ឲ្យឃើញថាថ្លៃទំនិញក្រុមម្ហូបអាហារមានឥទ្ធិពលយ៉ាងខ្លាំងក្នុងការជំរុញឲ្យអត្រាអតិផរណារួមកាន់តែខ្ពស់ ។ ដោយឡែក អត្រាអតិផរណាមិនរាប់បញ្ចូលក្រុមទំនិញនិងសេវាពាក់ព័ន្ធ និងប្រេងឥន្ធនៈដែលបញ្ចូលទាំងថ្លៃសេវាដឹកជញ្ជូនផងនោះមានអត្រា ៤,៨% ទិន្នន័យនេះ បង្ហាញថាថ្លៃប្រេងឥន្ធនៈ និងសេវាដឹកជញ្ជូនមានឥទ្ធិពលបន្តិចបន្តួចក្នុងការជំរុញឲ្យអតិផរណារួមកើនឡើង ។

### ១.២- ស្ថានភាពអត្រាប្តូរប្រាក់

#### ១.២.១- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក

អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១១នេះ មានស្ថិរភាពល្អប្រសើរគួរកត់សម្គាល់ ។ ជាក់ស្តែង បើគិតតាមអត្រាទិញទីផ្សារចុងគ្រា ប្រាក់រៀលមាននិន្នាការចុះថ្លៃ ដោយអត្រាប្តូរបានប្រែប្រួលពី ៤.០៤៨ រៀលក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ២០១០ មក ៤.០៥៧ រៀល ក្នុងមួយដុល្លារអាមេរិក នៅឆ្នាំ២០១១ ពោលគឺ ប្រាក់រៀលបានចុះថ្លៃ ០,២% ។

បើផ្អែកតាមអត្រាមធ្យមប្រចាំខែ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក បានធ្លាក់ចុះពី ៤.០៥៦ រៀល នាខែធ្នូ ឆ្នាំ២០១០ ដល់ ៤.០៣៦ រៀល នាគ្រាដូចគ្នានៅឆ្នាំ២០១១ ពោលគឺប្រាក់រៀលបានឡើងថ្លៃ ០,៥% ដោយសារការកើនឡើងនៃតម្រូវការប្រាក់រៀលនៅក្នុងសកម្មភាពសេដ្ឋកិច្ច កំណើនលំហូរចូលនៃដើមទុនមកក្នុងប្រទេស និងការចាប់ផ្តើមអនុវត្តការយកពន្ធលើអចលនទ្រព្យ ។ តាមការសង្កេត អត្រាប្តូរប្រាក់រៀលមានកម្រិតទាបជាងគេនៅខែមេសា ដែលមានអត្រា ៤.០១១ រៀល ក្នុងមួយដុល្លារអាមេរិក និងខ្ពស់ជាងគេនៅខែកក្កដា ដែលមានអត្រា ៤.១០៦ រៀល ក្នុងមួយដុល្លារអាមេរិក ។




| | អត្រាប្តូរប្រាក់ប្រចាំខែ (ចុងខែ) | | | | | |
|---|---|---|---|---|---|---|
| | អត្រាទីផ្សារ | | | អត្រាផ្លូវការ | | |
| | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម | អត្រាទិញ | អត្រាលក់ | អត្រាមធ្យម |
| ធ្នូ-១០ | ៤.០៤៨ | ៤.០៥៣ | ៤.០៥១ | ៤.០៥១ | ៤.០៥៥ | ៤.០៥៣ |
| មករា-១១ | ៤.០៥២ | ៤.០៥៩ | ៤.០៥៦ | ៤.០៥០ | ៤.០៥៤ | ៤.០៥២ |
| កុម្ភៈ-១១ | ៤.០៣៤ | ៤.០៣៨ | ៤.០៣៦ | ៤.០៣៦ | ៤.០៤២ | ៤.០៣៩ |
| មិនា-១១ | ៤.០០៤ | ៤.០១០ | ៤.០០៧ | ៤.០០៧ | ៤.០១៣ | ៤.០១០ |
| មេសា-១១ | ៤.០៦០ | ៤.០៦៩ | ៤.០៦៥ | ៤.០២០ | ៤.០២៨ | ៤.០២៤ |
| ឧសភា-១១ | ៤.០៩៤ | ៤.១០៣ | ៤.០៩៩ | ៤.០៨០ | ៤.០៨៨ | ៤.០៨៤ |
| មិថុនា-១១ | ៤.១២២ | ៤.១២៧ | ៤.១២៥ | ៤.១១៥ | ៤.១២៣ | ៤.១១៩ |
| កក្កដា-១១ | ៤.០៩៨ | ៤.១០៦ | ៤.១០២ | ៤.១០០ | ៤.១០៨ | ៤.១០៤ |
| សីហា-១១ | ៤.០៩៦ | ៤.១០៣ | ៤.១០០ | ៤.០៩៣ | ៤.១០១ | ៤.០៩៧ |
| កញ្ញា-១១ | ៤.០៨៤ | ៤.០៩៨ | ៤.០៩១ | ៤.០៨០ | ៤.០៨៨ | ៤.០៨៤ |
| តុលា-១១ | ៤.០៩២ | ៤.០៩៨ | ៤.០៩៥ | ៤.១០០ | ៤.១០៨ | ៤.១០៤ |
| វិច្ឆិកា-១១ | ៤.០៣០ | ៤.០៣៧ | ៤.០៣៤ | ៤.០៣១ | ៤.០៣៩ | ៤.០៣៥ |
| ធ្នូ-១១ | ៤.០៥៧ | ៤.០៦៦ | ៤.០៦២ | ៤.០៣៩ | ៤.០៣៩ | ៤.០៣៩ |

### ១.២.២- ស្ថានភាពអត្រាប្តូរប្រាក់រៀលធៀបនឹងរូបិយប័ណ្ណមួយចំនួន

ដោយផ្អែកលើអត្រាប្តូរប្រាក់ខ្វែងរវាងប្រាក់រៀលជាមួយរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជរបស់កម្ពុជាក្នុងឆ្នាំ២០១១ នេះ បានបង្ហាញថា ប្រាក់រៀលបានឡើងថ្លៃធៀបនឹង ប្រាក់ដុងវៀតណាម ៧,៧% ប្រាក់ដុល្លារតៃវ៉ាន់ ៤,៣% ប្រាក់បាតថៃ ៣,៧% ប្រាក់រីងហ្គីតម៉ាឡេស៊ី ៣,៦% ប្រាក់រូបពីឥណ្ឌូណេស៊ី ២,២% ប្រាក់ដុល្លារអូស្ត្រាលី ១,៧% ប្រាក់វ៉ុនកូរ៉េ ១,៧% ប្រាក់ដុល្លារសិង្ហបុរី ១,១% ប្រាក់ដុល្លារហុងកុង ០,៨% និងប្រាក់អឺរ៉ូ ០,៣% ។ ទន្ទឹមនឹងនោះដែរ ប្រាក់រៀលបានចុះថ្លៃធៀបនឹងប្រាក់យ៉េនជប៉ុន ៣,៩% និងប្រាក់យ៉ន់ចិន ៣,១% ។




### ១.២.៣- ស្ថានភាពអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបនឹងរូបិយប័ណ្ណមួយចំនួន

ការប្រៀបធៀបអត្រាប្តូរប្រាក់ដុល្លារអាមេរិកធៀបជាមួយរូបិយប័ណ្ណនៃប្រទេសជាដៃគូពាណិជ្ជកម្មរបស់កម្ពុជាក្នុងឆ្នាំ២០១១ នេះ បានបង្ហាញថា ប្រាក់ដុល្លារអាមេរិកបានឡើងថ្លៃធៀបនឹង ប្រាក់ដុងវៀតណាម ៧,៨% ប្រាក់ដុល្លារតៃវ៉ាន់ ៤,៣% ប្រាក់បាតថៃ ៣,៨% ប្រាក់រីងហ្គីតម៉ាឡេស៊ី ៣,២% ប្រាក់រូបពីឥណ្ឌូណេស៊ី ១,៨% ប្រាក់វ៉ុនកូរ៉េ ១,៥% ប្រាក់ដុល្លារអូស្ត្រាលី ១,៣% និងប្រាក់ដុល្លារសិង្ហបុរី ០,៦% ។ ទន្ទឹមនឹងនោះដែរ ប្រាក់ដុល្លារអាមេរិកបានចុះថ្លៃធៀបនឹង ប្រាក់យ៉េនជប៉ុន ៤,២% ប្រាក់យ៉ន់ចិន ៣,៤% ប្រាក់ប៉េសូហ្វីលីពីន ០,៥% និងប្រាក់អឺរ៉ូ ០,៣% ។




## ២- ការវិវត្តរូបិយវត្ថុ

សេដ្ឋកិច្ចប្រទេសកម្ពុជានៅឆ្នាំ ២០១១ នេះ ត្រូវបានរំពឹងថានឹងមានអត្រាកំណើនដល់ ៦,៩% ដែលអាចឆ្លុះបញ្ចាំងតាមរយៈការរីកចម្រើននៃវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម ព្រមទាំងវិស័យហិរញ្ញវត្ថុ ។ ជាក់ស្តែង បរិមាណឥណទានចំពោះវិស័យឯកជនបានបន្តកើនឡើង និងរូបិយវត្ថុទូទៅ (M2) ក៏មានកំណើនគួរឲ្យកត់សម្គាល់ផងដែរ ដែលក្នុងនោះប្រាក់បញ្ញើរបស់និវាសជននៅក្នុងប្រព័ន្ធធនាគារជាចំណែកមួយដ៏សំខាន់ ។ លើសពីនេះទៀត ទ្រព្យសកម្មបរទេសសុទ្ធ និងដើមទុនរបស់ប្រព័ន្ធធនាគារនៅតែបន្តរក្សាបានកំណើនជាបង្គួរ ដែលបង្ហាញនូវការកើនឡើងនៃជំនឿទុកចិត្តរបស់សាធារណជនមកលើប្រព័ន្ធធនាគារ ។



## ២.១- ការផ្គត់ផ្គង់រូបិយវត្ថុ

ក្នុងឆ្នាំ២០១១ នេះ រូបិយវត្ថុទូទៅ (M2) របស់ប្រព័ន្ធធនាគារបានកើនដល់ ២៣.៦៥៥ ពាន់លានរៀល ពោលគឺបានកើនឡើងចំនួន ៤.១៧៨ ពាន់លានរៀល ត្រូវនឹង ២១,៥% ធៀបនឹងឆ្នាំ២០១០ (២០%) និងឆ្នាំ២០០៩ (៣៦,៨%) ។ កំណើនរូបិយវត្ថុទូទៅនេះ រួមចំណែកចម្បងដោយការកើនឡើងនៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេសចំនួន ៣.២៩៤ ពាន់លានរៀល (២០,៨%) រូបិយវត្ថុក្នុងចរាចរណ៍ ៦៧៣ ពាន់លានរៀល (២១,៧%) ប្រាក់បញ្ញើមានកាលកំណត់ និងសន្សំ ១៤៩ ពាន់លានរៀល (៣៦,៤%) និងប្រាក់បញ្ញើចរន្ត ៦២ ពាន់លានរៀល (៥០,៩%) ។ គួរកត់សម្គាល់ផងដែរថា ប្រាក់បញ្ញើជារូបិយប័ណ្ណមានការកើនឡើងស្ទើរតែរាល់ខែ ដែលគិតជាមធ្យម ១,៦% ប្រហាក់ប្រហែលនឹងឆ្នាំ២០១០ (១,៨%) ។

ក្រាហ្វិកទី ៩ : សមាសធាតុនៃការផ្គត់ផ្គង់រូបិយវត្ថុ




### តារាងបម្រែបម្រួលជាភាគរយនៃស្ថិតិរូបិយវត្ថុសំខាន់ៗ និងសន្ទស្សន៍ថ្លៃទំនិញនិងសេវា

(បម្រែបម្រួលប្រចាំឆ្នាំជាភាគរយ)

| | ២០០៦ | ២០០៧ | ២០០៨ | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|---|---|
| ឥណទេយ្យសុទ្ធរាជរដ្ឋាភិបាល | -១២៦,៦ | -៩០,៥ | -៦៤,៥ | ២៤,៦ | ៥,៦ | ០,២ |
| ឥណទានផ្នែកឯកជន | ៥១,៦ | ៧៦,០ | ៥៥,០ | ៦,៥ | ២៦,៦ | ៣១,៧ |
| រូបិយវត្ថុទូទៅ (M2) | ៣៨,២ | ៦២,៩ | ៤,៨ | ៣៦,៨ | ២០,០ | ២១,៥ |
| រូបិយវត្ថុក្នុងចរាចរណ៍ | ២៤,៨ | ២៤,៤ | ១៥,៣ | ៣០,៨ | ៣,២ | ២១,៧ |
| អតិផរណាប្រចាំឆ្នាំ | ៤,២ | ១៤,០ | ១២,៣ | ៥,៣ | ៣,១ | ៤,៩ |

## ២.២- កត្តាជះឥទ្ធិពលដល់បរិមាណរូបិយវត្ថុ

ក្នុងឆ្នាំ២០១១ នេះ រូបិយវត្ថុទូទៅមានអត្រាកំណើនប្រហាក់ប្រហែលនឹងឆ្នាំ២០១០ ដែរ ។ ការកើនឡើងនៃរូបិយវត្ថុទូទៅនេះ ដោយសារកំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារចំនួន

១.១៩៦ ពាន់លានរៀល (៧,២%) គួបផ្សំនឹងកំណើននៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ ២.៩៨២ ពាន់លានរៀល (១០៧%) ផងដែរ ។ កំណើននៃទ្រព្យសកម្មបរទេសសុទ្ធរបស់ប្រព័ន្ធធនាគារនេះ ជាចម្បងបណ្តាលមកពីការកើនឡើងព្រមគ្នានៃទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាចំនួន ១.០២៨ ពាន់លានរៀល (៦,៩%) និងទ្រព្យសកម្មបរទេសសុទ្ធរបស់គ្រឹះស្ថានធនាគារ ១៦៨ ពាន់លានរៀល (៩,៨%) ។ ចំណែកឯការកើនឡើងនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ បណ្តាលមកពីកំណើននៃឥណទានចំពោះវិស័យឯកជន[២] ចំនួន ៤.២២២ ពាន់លានរៀល (៣១,៧%) ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ៣ ពាន់លានរៀល (០,២%) ខណៈដែលដើមទុន និងទុនបម្រុងរបស់ប្រព័ន្ធធនាគារបានកើនឡើង ១.០២៩ ពាន់លានរៀល (១១,៩) ។ នៅក្នុងលំហូរឥណទានចំពោះវិស័យឯកជនសរុប វិស័យដែលរួមចំណែកធំជាងគេមាន ឥណទានចំពោះតម្រូវការផ្ទាល់ខ្លួន ២១% វិស័យជួញដូររាយ ១៧% កសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ១៥% កម្មន្តសាល ១២% និងសំណង់ ១០% ។

### ២.២.១- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារជាតិនៃកម្ពុជា

ទ្រព្យសកម្មក្នុងស្រុកសុទ្ធរបស់ធនាគារជាតិនៃកម្ពុជាបានថយចុះចំនួន ២៣៩ ពាន់លានរៀល (៥,១%) ពោលគឺថយចុះពី -៤.៧៣៨ ពាន់លានរៀល នាខែធ្នូ ឆ្នាំ២០១០ មក -៤.៩៧៧ ពាន់លានរៀល ក្នុងឆ្នាំ២០១១ នេះ បន្ទាប់ពីបានថយចុះ ២៦៣ ពាន់លានរៀល (៤,៨%) នាឆ្នាំកន្លងទៅ ។ ការថយចុះនៃទ្រព្យសកម្មក្នុងស្រុកសុទ្ធ បណ្តាលមកពីការថយចុះឥណទេយ្យសុទ្ធពីបណ្តាធនាគារពាណិជ្ជចំនួន ១៣៧ ពាន់លានរៀល (៣១,៣%) ខ្ទង់ផ្សេងៗសុទ្ធ ១០៣ ពាន់លានរៀល (៤,១%) ខណៈដែលឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលមានការកើនឡើងតិចតួចចំនួន ១ ពាន់លានរៀល (០,១%) ។ ការកើននៃឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាលជារួមឆ្លុះបញ្ចាំងអំពីការថយចុះនៃប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាល ខណៈដែលឥណទានចំពោះរាជរដ្ឋាភិបាលមិនមានការប្រែប្រួល ។

ចំណែកឯទ្រព្យសកម្មបរទេសសុទ្ធវិញបានកើនឡើងចំនួន ១.០២៨ ពាន់លានរៀល (៦,៩%) ធៀបនឹងឆ្នាំ២០១០ ដែលមានកំណើន ១.៧២១ ពាន់លានរៀល (១៣%) ។ ការវិវត្តនេះបណ្តាលមកពីកំណើនទ្រព្យសកម្មបរទេសចំនួន ១.០២៥ ពាន់លានរៀល (៦,៦%) ខណៈដែលទ្រព្យអកម្មបរទេសថយចុះតិចតួចចំនួន ៣ ពាន់លានរៀល (០,៧%) ។

### ២.២.២- ទ្រព្យសកម្មក្នុងស្រុកសុទ្ធ និងទ្រព្យសកម្មបរទេសសុទ្ធរបស់ធនាគារពាណិជ្ជ

ក្នុងឆ្នាំ២០១១ នេះ ទ្រព្យសកម្មសរុបរបស់បណ្តាធនាគារពាណិជ្ជមានកម្រិត ៣២.៣១៦ ពាន់លានរៀល ពោលបានកើនឡើង ៦.៤៨៩ ពាន់លានរៀល (២២,២%) ដែលជួយទ្រទ្រង់ដល់កំណើនឥណទានរបស់ធនាគារ និងរួមចំណែកដល់ការធ្វើហិរញ្ញប្បទានសកម្មភាពវិនិយោគនៅក្នុងប្រទេស ។ ការកើនឡើងនៃទ្រព្យសកម្មសរុបនៅក្នុងប្រព័ន្ធធនាគារ ឆ្លុះបញ្ចាំងមួយផ្នែកដោយការបង្កើនដើមទុនរបស់ធនាគារដែលមានស្រាប់ ដើមទុនរបស់គ្រឹះស្ថានធនាគារដែលបើកថ្មី និងការកើនឡើងប្រាក់បញ្ញើរបស់អតិថិជន ។ ប្រាក់បញ្ញើសរុបមានចំនួន ១៩.៨៣០ ពាន់លានរៀល បានកើនឡើង ៣.៤៧៩ ពាន់លានរៀល (២១,៣%) ដែលក្នុងនោះប្រាក់បញ្ញើជារូបិយប័ណ្ណមានសមាមាត្រ ៩៧% នៃប្រាក់បញ្ញើសរុបរបស់អតិថិជន ។

ទ្រព្យសកម្មក្នុងស្រុកសុទ្ធបានកើនឡើងចំនួន ៣.៥៣៦ ពាន់លានរៀល (៤៩,២%) ។ បម្រែបម្រួលនេះ ជាចម្បងបណ្តាលមកពីការកើនឡើងនៃឥណទានចំពោះវិស័យឯកជនចំនួន ៤.២២២ ពាន់លានរៀល (៣១,៧%) ឥណទេយ្យសុទ្ធចំពោះរាជរដ្ឋាភិបាល ២ ពាន់លានរៀល (០,៧%) ខណៈដែលខ្ទង់ផ្សេងៗសុទ្ធថយចុះ ៦៨៦ ពាន់លានរៀល (១១,៨%) ។ ការថយចុះនៃខ្ទង់ផ្សេងៗសុទ្ធ ជាលទ្ធផលនៃការកើនឡើងនៃដើមទុននិងទុនបម្រុងចំនួន ៨៧២ ពាន់លានរៀល (១៥,៧%) ទ្រព្យអកម្មផ្សេងៗ ៥៨៦ ពាន់លានរៀល (៤៣,១%) និងបំណុលអន្តរធនាគារ ៣៩៦ ពាន់លានរៀល (៤១,៥%) នៅពេលដែលទ្រព្យសកម្មផ្សេងៗកើនឡើង ១.១៧៥ ពាន់លានរៀល (៥៦,៤%) ។ ទន្ទឹមនេះដែរ ប្រាក់បញ្ញើរបស់បណ្តាធនាគារពាណិជ្ជនៅធនាគារជាតិនៃកម្ពុជាដែលជាធាតុផ្សំនៃទុនបម្រុងអន្តរជាតិបានថយចុះ ២៦១ ពាន់លានរៀល (៣,៦%) ។

ទ្រព្យសកម្មបរទេសសុទ្ធរបស់បណ្តាធនាគារពាណិជ្ជបានកើនពី ១.៧១៥ ពាន់លានរៀល នាឆ្នាំ២០១០ ទៅ ១.៨៨៤ ពាន់លានរៀល នាឆ្នាំ២០១១ ត្រូវនឹងកំណើន ១៦៨ ពាន់លានរៀល (៩,៨%) ។ ការកើនឡើងនេះបណ្តាលមកពីកំណើនទ្រព្យសកម្មបរទេសចំនួន ៦៧៥ ពាន់លានរៀល (១៩,២%) ដែលត្រូវបានផាត់ទាត់មួយផ្នែកដោយកំណើនទ្រព្យអកម្មបរទេស ៥០៦ ពាន់លានរៀល (២៨,២%) ។

### ២.៣- អត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ

សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញក្នុងល្បឿនគួរឲ្យកត់សម្គាល់ពីកម្រិត ០,១% នៅឆ្នាំ២០០៩ មក ៦% នាឆ្នាំ២០១០ និងបន្តមានកំណើនជាង ៦% នៅឆ្នាំ២០១១ ខណៈដែលអត្រាអតិផរណាចុងគ្រាឆ្នាំលើឆ្នាំ ស្ថិតក្នុងកម្រិតមួយខ្ទង់ ៦,៧% និងអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិក ស្មើនឹង ៤.០៣០ រៀល ក្នុង ១ដុល្លារអាមេរិក ។

ការពិនិត្យលើបម្រែបម្រួលអត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជ បានបង្ហាញថា អត្រាការប្រាក់រយៈពេល ៦ខែ វាស់ដោយកម្រិតមធ្យមថ្លឹងតាមទំហំនៃប្រតិបត្តិការធនាគារ មាននិន្នាការថយចុះទាំងប្រាក់បញ្ញើ និងទាំងឥណទាន ។ ក្នុងនេះ អត្រាការប្រាក់បញ្ញើមានការថយចុះតិចតួច ពោលគឺ អត្រាការប្រាក់បញ្ញើជារៀលបានថយចុះចំនួន ០,១% ពី ៥,៤៩% នាខែធ្នូ ឆ្នាំ២០១០ មក ៥,៣៩% នៅដំណាច់ឆ្នាំ២០១១ និងអត្រាការប្រាក់បញ្ញើជាប្រាក់ដុល្លារអាមេរិកបានថយចុះចំនួន ០,០៩% ពី ៣,៥០% នាខែធ្នូ ឆ្នាំ២០១០ មក ៣,៤១% នាខែធ្នូ ឆ្នាំ២០១១ ។ អត្រាការប្រាក់កម្ចីមានការធ្លាក់ចុះ ពោលគឺ អត្រាការប្រាក់កម្ចីជារៀលបានថយចុះចំនួន ៦,០៣% ពី ២១,៥៧% នាខែធ្នូ ឆ្នាំ២០១០ មក ១៥,៥៤% នៅដំណាច់ឆ្នាំ២០១១ និងអត្រាការប្រាក់កម្ចីជាប្រាក់ដុល្លារអាមេរិកបានថយចុះចំនួន ៣,៣៩% ពី ១៨,៩៦% នាខែធ្នូ ឆ្នាំ២០១០ មក ១៥,៥៧% នាខែធ្នូ ឆ្នាំ២០១១ ។



ក្រាហ្វស្ថិតិ ១០: **អត្រាការប្រាក់កម្ចី និងប្រាក់បញ្ញើ**
(អត្រាមធ្យម ៦ ខែ)

តាមរយៈការថយចុះនៃអត្រាការប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ បានបណ្តាលឲ្យគម្លាតអត្រាការប្រាក់ជារៀលបានថយចុះពី ១៦,០៨% នាខែធ្នូ ឆ្នាំ២០១០ មក ១០,១៥% នៅដំណាច់ឆ្នាំ២០១១ ។ ចំណែកឯគម្លាតអត្រាការប្រាក់ជាដុល្លារបានថយចុះពី ១៥,៤៦% នាខែធ្នូ ឆ្នាំ២០១០ មក ១២,១៦% នៅខែធ្នូ ឆ្នាំ២០១១ ។ នេះសឲ្យឃើញថា អន្តរការិយកម្មធនាគារមានការរីកចម្រើន និងមានភាពរឹងមាំគួរជាទីទុកចិត្ត ។

**តារាងអត្រាការប្រាក់លើប្រាក់កម្ចី និងប្រាក់បញ្ញើ ( អត្រាមធ្យម ៦ខែ - ជាភាគរយ )**

| | ធ្នូ ២០១០ | មករា ២០១១ | កម្ភៈ ២០១១ | មីនា ២០១១ | មេសា ២០១១ | ឧសភា ២០១១ | មិថុនា ២០១១ | កក្កដា ២០១១ | សីហា ២០១១ | កញ្ញា ២០១១ | តុលា ២០១១ | វិច្ឆិកា ២០១១ | ធ្នូ ២០១១ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| អត្រាការប្រាក់បញ្ញើជារៀល | ៥,៤៩ | ៥,៤៩ | ៥,៤៩ | ៥,៤៣ | ៥,៤៣ | ៥,៤៣ | ៥,៤២ | ៥,៤៣ | ៥,៤៣ | ៥,៤៣ | ៥,៤៤ | ៥,៣៩ | |
| អត្រាការប្រាក់កម្ចីជារៀល | ២១,៥៧ | ២១,៥០ | ២១,៥៤ | ២១,៤៤ | ២១,៣៤ | ២១,៤៤ | ១៤,៨០ | ១៤,៧០ | ១៤,៧០ | ១៤,៧០ | ១៤,៧០ | ១៥,៥៤ | |
| គម្លាត | ១៦,៥៥ | ១២,៩៦ | ១២,៩៦ | ១៦,០១ | ១៥,៩១ | ១៦,០១ | ៩,៣៨ | ៩,២៣ | ៩,២៣ | ៩,២៣ | ៩,២៦ | ១០,១៥ | |
| | | | | | | | | | | | | | |
| អត្រាការប្រាក់បញ្ញើជាដុល្លារ | ៣,៥០ | ៣,៤៥ | ៣,៤៦ | ៣,៤៣ | ៣,៤២ | ៣,៤២ | ៣,៤៤ | ៣,៣៩ | ៣,៤៤ | ៣,៤០ | ៣,៤០ | ៣,៤១ | |
| អត្រាការប្រាក់កម្ចីជាដុល្លារ | ១៨,៩៦ | ១៦,៧៥ | ១៦,៧១ | ១៦,៦៩ | ១៧,៣៦ | ១៨,៨១ | ១៥,៣៧ | ១៥,៣៩ | ១៥,៣៩ | ១៥,៥៩ | ១៥,៤០ | ១៥,៥៧ | |
| គម្លាត | ១៥,៤៦ | ១៣,៣០ | ១៣,២៥ | ១៣,២៦ | ១៣,៩៤ | ១៥,៣៩ | ១១,៩៣ | ១២,០០ | ១១,៩៥ | ១២,១៩ | ១២,០០ | ១២,១៦ | |

## ៣- ជញ្ជីងទូទាត់

ខណៈដែលសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងតំបន់អឺរ៉ុបនៅជួបប្រទះនឹងបញ្ហាប្រឈមជាច្រើនក្តី សេដ្ឋកិច្ចក្នុងតំបន់បន្តរក្សាកំណើនក្នុងកម្រិតគួរកត់សម្គាល់ ។ ប៉ុន្តែស្ថានភាពដែលគួរឲ្យកត់សម្គាល់គឺ តម្រូវការនៅក្នុងប្រទេសអភិវឌ្ឍន៍មិនបានស្រុកស្រុតខ្លាំង ដែលធ្វើឲ្យមានផលប៉ះពាល់ដល់ប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាឡើយ ។ ករណីនេះត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញនៅក្នុងលទ្ធផលប្រសើរឡើងនៃគណនីសំខាន់ៗរបស់ជញ្ជីងទូទាត់ ។ ជាក់ស្តែង សមតុល្យគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្លូវការ) មានឱនភាព ១.០១១ លានដុល្លារអាមេរិក (៨% នៃផសស) ធៀបនឹង ១.១៧១ លានដុល្លារអាមេរិក (១០%នៃផសស) នៅឆ្នាំ២០១០ ។ ទន្ទឹមនោះ សមតុល្យគណនីបង្វែរផ្លូវការ និងគណនីហិរញ្ញវត្ថុមានអតិរេក ១.២៧៦ លានដុល្លារអាមេរិក ។ ជាលទ្ធផល សមតុល្យរួមមានអតិរេកចំនួន ២១៥ លានដុល្លារអាមេរិក ឬ ១,៧% នៃផសស បានកើនឡើង ៦៥ លានដុល្លារអាមេរិក (៤៣,៣%) ធៀបនឹងឆ្នាំ២០១០ ។

### ៣.១- គណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ)

ការប៉ាន់ស្មានដំបូងបានបង្ហាញថា សមតុល្យគណនីចរន្ត (មិនរាប់បញ្ចូលបង្វែរផ្ទេរការ) មានឱនភាពចំនួន ១.០១១ លានដុល្លារអាមេរិក បានថយចុះ ១៦០ លានដុល្លារអាមេរិក (១៣,៧%) ធៀបនឹងឆ្នាំ២០១០ ។ ឱនភាពគណនីចរន្តមានសមាមាត្រប្រមាណ ៨% នៃផលិតផលក្នុងស្រុកសរុប ។ មូលហេតុចម្បងនៃការថយចុះឱនភាពគណនីចរន្តនេះ បណ្តាលមកពីការថយចុះឱនភាពគណនីទំនិញប្រមាណ ៦,៣% ខណៈដែលឱនភាពគណនីប្រាក់ចំណូលបានកើនឡើងប្រមាណ ៧,៤% ។ ឱនភាពគណនីចរន្តនេះ ត្រូវបានផាត់ទាត់ដោយការកើនឡើងនៃអតិរេកគណនីសេវាសុទ្ធចំនួន ១៣,៩% ។

ក្រាហ្វស្ថិតិ ១១ : **ជញ្ជីងពាណិជ្ជកម្ម (ឆ្នាំ១៩៩៨-២០១១)**




ការនាំចេញសរុបនៃផលិតផលក្នុងស្រុកមានការកើនឡើងចំនួន ៨៧៧ លានដុល្លារអាមេរិក (២៤,២%) ធៀបនឹងឆ្នាំ២០១០ ។ កត្តាសំខាន់ជំរុញឲ្យមានកំណើននេះគឺការនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌដែលមានសមាមាត្រដល់ទៅជាង ៩៥% នៃការនាំចេញសរុបនៃផលិតក្នុងស្រុក ។ ក្នុងអំឡុងនេះដែរ ការនាំចេញសម្លៀកបំពាក់និងវាយនភ័ណ្ឌមានចំនួន ៤.២៩៥ លានដុល្លារអាមេរិក បានកើនឡើង ៨៥៩ លានដុល្លារអាមេរិក (២៥%) ធៀបនឹងឆ្នាំ២០១០ ។ ស្របពេលជាមួយគ្នានេះ ការនាំចេញផលិតផលក្នុងស្រុកផ្សេងទៀតបានកើនឡើងប្រមាណ ១០% ។ ការកើនឡើងនៃតម្លៃផលិតផលស្រូវ ត្រី និងកៅស៊ូ បានរួមចំណែកក្នុងការកើនឡើងតម្លៃនៃការនាំចេញផលិតផលក្នុងស្រុកនេះ ។

ការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកត្រូវបានប៉ាន់ស្មានថាមានចំនួន ៥.៩៨២ លានដុល្លារអាមេរិក បានកើនឡើង ៧២០ លានដុល្លារអាមេរិក (១៣,៧%) ធៀបនឹងឆ្នាំ ២០១០ ។ កត្តាដែលរួមចំណែកយ៉ាងសំខាន់ក្នុងការកើនឡើងការនាំចូលទំនិញសម្រាប់ប្រើប្រាស់ក្នុងស្រុកនេះ គឺការនាំចូលវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ដែលបានកើនឡើង ២៧២ លានដុល្លារអាមេរិក (២០%) ។ ការនាំចូលប្រេងឥន្ធនៈបានកើនឡើងប្រមាណ ៧០ លានដុល្លារអាមេរិក (១៥%) ហើយតម្លៃនៃការនាំចូលប្រេងឥន្ធនៈនេះ កើនឡើងដោយសារថ្លៃក្នុងមួយឯកតាគិតជាមធ្យមបានកើនឡើង ១០០% ខណៈដែលបរិមាណនៃការនាំចូលកើនឡើងតែ ៨% ប៉ុណ្ណោះ ធៀបនឹងឆ្នាំ២០១០ ។ ក្នុងអំឡុងឆ្នាំ២០១១ នេះដែរ ការ

នាំចូលអគ្គិសនីបានកើនឡើងប្រមាណ ៤៥ លានដុល្លារអាមេរិក (៤៣%) ហើយការនាំចូលទំនិញផ្សេងទៀតសម្រាប់ប្រើប្រាស់ក្នុងស្រុកបានកើនឡើង ៣៣៣ លានដុល្លារអាមេរិក (១០%) ធៀបនឹងឆ្នាំ២០១០ ។

គណនីសេវាសុទ្ធត្រូវបានប៉ាន់ស្មានថា មានអតិរេកចំនួន ៧៩៤ លានដុល្លារអាមេរិក បានកើនឡើង ៩៧ លានដុល្លារអាមេរិក (១៣,៩%) ធៀបនឹងឆ្នាំ២០១០ ។ លទ្ធផលនៃអតិរេកនេះ ដោយសារកំណើននៃប្រាក់ចំណូលពីសេវាបានកើនឡើង ១២១ លានដុល្លារអាមេរិក (៧,២%) ខណៈដែលចំណាយទូទាត់សេវាឲ្យទៅអនិវាសជនបានកើនឡើង ២៤ លានដុល្លារអាមេរិក (២,៤%) ។ ចំណូលពីសេវាទេសចរណ៍ បានរួមចំណែកយ៉ាងខ្លាំងដល់កំណើនប្រាក់ចំណូលពីសេវា ដែលត្រូវបានប៉ាន់ស្មានថាមានចំនួន ១.២៧៤ លានដុល្លារអាមេរិក បានកើនឡើង ៩៤ លានដុល្លារអាមេរិក (៨%) ធៀបនឹងឆ្នាំ២០១០ ។

គណនីប្រាក់ចំណូលសុទ្ធមានឱនភាពចំនួន ៥៦៩ លានដុល្លារអាមេរិក បានកើនឡើង ៣៩ លានដុល្លារអាមេរិក (៧,៤%) ធៀបនឹងឆ្នាំ២០១០ ។ ការកើនឡើងឱនភាពនេះ បណ្តាលមកពីការកើនឡើងការផ្ទេរប្រាក់ចេញទៅឲ្យអនិវាសជន ៣៩ លានដុល្លារអាមេរិក ក្នុងនោះ ការផ្ទេរប្រាក់ចំណូលពីការវិនិយោគនៅកម្ពុជាបានកើនឡើង ៣៥ លានដុល្លារអាមេរិក ។ គណនីបង្វែរឯកជនសុទ្ធមានអតិរេក ២៤៥ លានដុល្លារអាមេរិក បានកើនឡើងជាង ២ លានដុល្លារអាមេរិក (១%) ធៀបនឹងឆ្នាំ២០១០ ។

**៣.២- គណនីបង្វែរផ្លូវការ និងហិរញ្ញវត្ថុ**

គណនីបង្វែរផ្លូវការសុទ្ធមានស្ថិរភាពជាច្រើនធៀបនឹងឆ្នាំកន្លងទៅ ដោយមានចំនួន ៧២៣ លានដុល្លារអាមេរិក នៅឆ្នាំ២០១១ ធៀបនឹង ៧៣១ លានដុល្លារអាមេរិក នៅឆ្នាំ២០១០ ដែលឆ្លុះបញ្ចាំងស្ទើរតែទាំងស្រុងនូវប្រតិបត្តិការចំណូលជាហិរញ្ញប្បទានសហប្រតិបត្តិការឥតសំណង ។ ក្នុងអំឡុងពេលនេះដែរ គណនីហិរញ្ញវត្ថុមានអតិរេក ៥៥៣ លានដុល្លារអាមេរិក ធៀបនឹង ៦២០ លានដុល្លារអាមេរិក នៅឆ្នាំ២០១០ បានថយចុះ ១០,៨% ។ ប្រតិបត្តិការនេះឆ្លុះបញ្ចាំងលំហូរកម្ចីផ្លូវការ និងលំហូរដើមទុនឯកជន ។ លំហូរជាជំនួយប្រាក់កម្ចីផ្លូវការសុទ្ធត្រូវបានប៉ាន់ស្មានថាមានចំនួន ២០៨ លានដុល្លារអាមេរិក បានថយចុះ ៣៧ លានដុល្លារអាមេរិក (១៥,១%) ធៀបនឹងលំហូរនៃឆ្នាំកន្លងទៅ ។

ក្រាហ្វស្ថិតិ ១២ : **ជញ្ជីងទូទាត់កម្ពុជា (ឆ្នាំ១៩៩៨-២០១១)**




ដោយឡែក លំហូរដើមទុនឯកជនត្រូវបានឆ្លុះបញ្ចាំងជាបឋមដោយលំហូរវិនិយោគផ្ទាល់បរទេសសុទ្ធ ខណៈវិនិយោគលើផលបត្រមានកម្រិតតិចតួច ។ លំហូរវិនិយោគផ្ទាល់បរទេសសុទ្ធមានចំនួន ៦៧៧ លានដុល្លារអាមេរិក បានថយចុះ ៨៤ លានដុល្លារអាមេរិក (១១,១%) ធៀបនឹងឆ្នាំ២០១០ ដែលឆ្លុះបញ្ចាំងការថយចុះវិនិយោគបរទេសក្នុងវិស័យធនាគារ ៦៦,៧% ខណៈដែលវិនិយោគសុទ្ធក្នុងវិស័យមិនមែនធនាគារកើនឡើង ១១៥ លានដុល្លារអាមេរិក (២៥%) ក្នុងនោះ វិនិយោគបរទេសផ្នែកវាយនភ័ណ្ឌ កសិឧស្សាហកម្ម និងទូរគមនាគមន៍ មានការកើនឡើងគួរឲ្យកត់សម្គាល់ ។

ក្រាហ្វស្ថិតិ ១៣ : **លំហូរវិនិយោគផ្ទាល់បរទេស (ឆ្នាំ១៩៩៨-២០១១)**



សរុបមក ការថយចុះនៃអតិរេកគណនីបង្វែរផ្លូវការ និងគណនីហិរញ្ញវត្ថុ ត្រូវបានផាត់ទាត់ដោយការថយចុះនៃឱនភាពគណនីចរន្តក្នុងទំហំខ្ពស់ជាង ដែលធ្វើឲ្យប្រតិបត្តិការជញ្ជីងទូទាត់របស់ប្រទេសកម្ពុជាក្នុងឆ្នាំ២០១១ នេះ មានអតិរេកចំនួន ២១៥ លានដុល្លារអាមេរិក ។ ជាលទ្ធផល ទុនបម្រុងអន្តរជាតិបានកើនឡើងដល់ជាង ៣ ពាន់លានដុល្លារអាមេរិក ដែលអាចទ្រទ្រង់ និងទូទាត់ការនាំចូលទំនិញនិងសេវាបាន ៤,៩ ខែ ។

## ៤- ការគ្រប់គ្រងទុនបម្រុងអន្តរជាតិ

### ៤.១- ការងារវិនិយោគទុនបម្រុងអន្តរជាតិ

ធនាគារជាតិនៃកម្ពុជាវិនិយោគទុនបម្រុងអន្តរជាតិក្រោមរូបភាពជាអូវើណាយ (Overnight) ប័ណ្ណរតនាគារអាមេរិក (US Treasury Bills) ឧបករណ៍ហិរញ្ញវត្ថុរយៈកាលមធ្យម (MTI) និងប្រាក់បញ្ញើរយៈកាលខ្លីជាមួយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារកណ្តាលនៃប្រទេសអភិវឌ្ឍន៍ធំៗ និងគ្រឹះស្ថានធនាគារពាណិជ្ជដែលមានស្តង់ដារនិងក្រេឌីតរ៉េទីងខ្ពស់ ។ ទន្ទឹមនេះ ទុនបម្រុងមួយចំណែកតូចក៏ត្រូវបានវិនិយោគតាមរយៈអ្នកចាត់ការខាងក្រៅផងដែរ ។

ទុនបម្រុងអន្តរជាតិ ត្រូវបានវិនិយោគតាមគោលការណ៍កំណត់ដោយគណៈកម្មការវិនិយោគ និងដោយប្រុងប្រយ័ត្នតាមលំដាប់អាទិភាព ទី១-សុវត្ថិភាព ទី២-សន្ទនីយភាព និងទី៣-ប្រាក់ចំណូល ។ ការកំណត់ឥណប្រតិទាន ការជ្រើសរើសដៃគូ និងការកំណត់ឧបករណ៍វិនិយោគ ត្រូវបានអនុវត្តតាមសេចក្តីណែនាំការវិនិយោគដែលអនុម័តដោយគណៈកម្មការវិនិយោគ ។

នៅក្នុងឆ្នាំ២០១១ សេដ្ឋកិច្ចសហរដ្ឋអាមេរិកនិងអង់គ្លេស នៅមិនទាន់មានស្ថានភាពប្រសើរឡើងវិញទាំងស្រុងទេ ហើយអត្រាការប្រាក់គោលប្រាក់ដុល្លារអាមេរិកនិងប្រាក់ផោនអង់គ្លេស ត្រូវបានបន្តរក្សាត្រឹម ០,២៥% និង ០,៥% រៀងគ្នា ដដែល ។ ដោយឡែក ធនាគារកណ្តាលអឺរ៉ុបដែលបានតម្លើងអត្រាការប្រាក់គោលចំនួនពីរលើក ពី ១% ដល់ ១,៥០% បានសម្រេចកាត់បន្ថយអត្រាការប្រាក់គោលពីរលើកចំនួន ៥០ ពិន្ទុ វិញ ពី ១,៥០% មកនៅត្រឹម ១% ។ ទន្ទឹមនេះ ធនាគារកណ្តាលអូស្ត្រាលីដែលបានរក្សាអត្រាការប្រាក់គោលប្រាក់ដុល្លារអូស្ត្រាលីនៅត្រឹម ៤,៧៥% ក៏បានសម្រេចកាត់បន្ថយអត្រាការប្រាក់គោលចំនួន ៥០ ពិន្ទុ ពី ៤,៧៥% មកនៅត្រឹម ៤,២៥% ដើម្បីទប់ទល់នឹងការធ្លាក់ចុះនៃសេដ្ឋកិច្ច ។

គិតត្រឹមដំណាច់ឆ្នាំ២០១១ ទុនបម្រុងអន្តរជាតិសរុបដែលបានវិនិយោគគិតជាប្រាក់ដុល្លារអាមេរិក (ដោយមិនរាប់បញ្ចូលមាសចំនួន ១២.៤៣៦ គីឡូក្រាម និងប្រាក់ SDR ចំនួន ៦៨ លាន SDR) មានចំនួន ៣.២១៣ លានដុល្លារអាមេរិក កើនឡើងចំនួន ៤,៨៦% ធៀបនឹងចុងខែធ្នូឆ្នាំ២០១០ (៣.០៦៤ លានដុល្លារអាមេរិក) ។

### ៤.២. អន្តរាគមន៍នៅលើទីផ្សារប្តូរប្រាក់

នៅក្នុងឆ្នាំ២០១១ ការអន្តរាគមន៍លក់ប្រាក់ដុល្លារអាមេរិកមិនត្រូវបានអនុវត្តទេ ដោយសារតម្លៃប្រាក់រៀលមានស្ថិរភាពល្អ ។ ផ្ទុយទៅវិញ ការអន្តរាគមន៍លក់ប្រាក់រៀលដើម្បីបំពេញតម្រូវការសេដ្ឋកិច្ចមានទឹកប្រាក់សរុបចំនួន ៨៣៧ ពាន់លានរៀល សមមូលនឹងជាង ២០៦ លានដុល្លារអាមេរិក ។

ក្នុងអំឡុងឆ្នាំនេះដែរ ធនាគារជាតិនៃកម្ពុជាបានទិញប្រាក់ដុល្លារអាមេរិកពីក្រសួងសេដ្ឋកិច្ចនិង

ហិរញ្ញវត្ថុចំនួន ៥២ លានដុល្លារអាមេរិក និងលក់ជូនក្រសួងវិញ ៧៦ លានដុល្លារអាមេរិក ។ ទន្ទឹមនឹងនោះ ធនាគារជាតិនៃកម្ពុជាក៏បានទិញប្រាក់ដុល្លារអាមេរិកពីក្រុមហ៊ុនអគ្គិសនីកម្ពុជាចំនួន ៧ លានដុល្លារអាមេរិក និងបានលក់ជូនវិញចំនួន ៥៤ លានដុល្លារអាមេរិកផងដែរ ។

### ៤.៣. ការងារប្រតិវេទន៍ និងការផ្តល់អាជ្ញាប័ណ្ណនាំចេញ-នាំចូលលោហធាតុ និងត្បូងថ្មមានតម្លៃ

#### ៤.៣.១. ការងារប្រតិវេទន៍

នៅក្នុងឆ្នាំ២០១១នេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់ទិដ្ឋាការលើប្រតិវេទន៍នាំចូលមាសចំនួន ១៣ លើក ដែលមានទម្ងន់សរុបចំនួន ៥.៩០០ គីឡូក្រាម និងនាំចេញមាសចំនួន ២ លើក ដែលមានទម្ងន់សរុបចំនួន ៦០០ គីឡូក្រាម ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់ទិដ្ឋាការលើប្រតិវេទន៍នាំចេញរូបិយប័ណ្ណចម្រុះចំនួន ១ លើក ដែលមានទឹកប្រាក់សរុបជាង ២ លានដុល្លារអាមេរិក ។

#### ៤.៣.២. ការផ្តល់អាជ្ញាប័ណ្ណនាំចេញ-ចូល លោហធាតុនិងត្បូងថ្មមានតម្លៃ

យោងប្រកាសលេខ ធ៩-២៦២ប្រ.ក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការផ្តល់អាជ្ញាប័ណ្ណនាំចេញ-ចូលលោហធាតុនិងត្បូងថ្មមានតម្លៃ ធនាគារជាតិនៃកម្ពុជាបានចេញអាជ្ញាប័ណ្ណ ចំនួន ១៧ ច្បាប់ នៅក្នុងឆ្នាំ២០១១ ។

## ៥- សម្ព័ន្ធការងារជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

ប្រព័ន្ធធនាគារក្នុងប្រទេសកម្ពុជាមានវឌ្ឍនភាព និងពង្រីកខ្លួនជាលំដាប់ ដើម្បីសម្របតាមការអភិវឌ្ឍឥតឈប់ឈរនៃសេដ្ឋកិច្ច ។ ចំនួនគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបាននិងកំពុងកើនឡើងគួរឲ្យកត់សម្គាល់ក្នុងអំឡុងពេល៥ឆ្នាំចុងក្រោយ ។ គិតត្រឹមដំណាច់ឆ្នាំ២០១១ នេះ ប្រព័ន្ធធនាគារក្នុងប្រទេសកម្ពុជា រួមមានធនាគារពាណិជ្ជចំនួន ៣១ ធនាគារឯកទេសចំនួន ៧ ការិយាល័យតំណាងធនាគារបរទេសចំនួន ២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣១ ក្នុងនោះគ្រឹះស្ថានចំនួន ៧ អនុញ្ញាតឲ្យទទួលប្រាក់បញ្ញើពីសាធារណជន និងប្រតិបត្តិករឥណទានជនបទចំនួន ២៨ ។

បណ្តាញសាខានៅតាមរាជធានី-ខេត្ត បានបន្តកើនឡើងជាបន្តបន្ទាប់ ។ ជាក់ស្តែងក្នុងឆ្នាំ២០១១ នេះ គ្រឹះស្ថានធនាគារបានបើកសាខាថ្មីសរុបចំនួន ២៨ ដែលធ្វើឲ្យចំនួនសាខាកើនដល់ ៤២១ ហើយក៏មានគ្រឹះស្ថានធនាគារមួយចំនួនបាននិងកំពុងដាក់ពាក្យសុំបើកសាខាថ្មីផងដែរ ។ លើសពីនេះទៀត គ្រឹះស្ថានធនាគារខ្លះនៅកម្ពុជា បានបើកសាខានៅប្រទេសឡាវ និងប្រទេសវៀតណាម ។

នៅក្នុងឆ្នាំ២០១១ អនុបាតឥណទានធៀបនឹងប្រាក់បញ្ញើបានកើនឡើងដល់ ៨៣,៣% ធៀបនឹងដំណាច់ឆ្នាំ២០១០ ដែលមានត្រឹម ៧៥,១% ដោយឥណទានដែលបានផ្តល់ដល់អតិថិជននៅក្នុងឆ្នាំនេះមានកំណើនដល់ ៣៣,៥% និងកម្រិតប្រាក់បញ្ញើអតិថិជនមានកំណើនត្រឹមតែ ២០% ធៀបនឹងឆ្នាំមុន ។

ជារួម ប្រតិបត្តិការធនាគារមានសន្ទុះគួរឲ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈសូចនាករមួយចំនួនដូចជា ការកើនឡើងនៃចំនួនធនាគារនិងសាខា ម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ ព្រមទាំងចំនួនអតិថិជនខ្ចី និងដាក់ប្រាក់បញ្ញើ ។

## ៥.១. ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

### ៥.១.១. ការត្រួតពិនិត្យលើឯកសារ

ចំពោះការអនុវត្តតាមលក្ខខណ្ឌនៃដើមទុនថ្មី គ្រឹះស្ថានធនាគារបានអនុវត្តល្អប្រសើរតាមលក្ខខណ្ឌកំណត់ ហើយមិនតែប៉ុណ្ណោះ គ្រឹះស្ថានធនាគារមួយចំនួនបានស្នើសុំបង្កើនដើមទុនអប្បបរមាខ្ពស់ជាងកម្រិតកំណត់ផង ។ ទន្ទឹមនេះដែរ សាខាធនាគារបរទេសមួយបានប្ដូរមកជាធនាគារក្នុងស្រុក និងមួយទៀតកំពុងដំណើរការប្រែក្លាយជាធនាគារក្នុងស្រុក ។ នៅក្នុងឆ្នាំ២០១១ នេះដែរ គ្រឹះស្ថានធនាគារមួយចំនួនបានស្នើសុំផ្ដល់សេវាថ្មី ដូចជា សេវាសន្សំជាមាស និងសេវាតាមប្រព័ន្ធអេឡិចត្រូនិក ។

ធនាគារជាតិនៃកម្ពុជាបន្តតាមដាន និងវិភាគស្ថានភាពហិរញ្ញវត្ថុរបស់គ្រឹះស្ថានធនាគារដោយផ្អែកលើវិធីសាស្ត្រ COBRA ដើម្បីពិនិត្យលើភាពរឹងមាំ និងតម្លាភាពហិរញ្ញវត្ថុ និងដាក់វិធានការកែតម្រូវឲ្យបានទាន់ពេលវេលា បើគ្រឹះស្ថានមិនអនុវត្តតាមបទប្បញ្ញត្តិជាធរមាន ។ ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជានឹងបន្តតាមដានការអនុវត្តតាមប្រកាសស្ដីពី ការត្រួតពិនិត្យផ្ទៃក្នុងរបស់គ្រឹះស្ថានធនាគារ ដែលជាផ្នែកមួយដ៏សំខាន់ក្នុងការពង្រឹងអភិបាលកិច្ចល្អក្នុងគ្រឹះស្ថានធនាគារ ។

### ៥.១.២ ការងារត្រួតពិនិត្យដល់ទីកន្លែង

ការត្រួតពិនិត្យដល់ទីកន្លែង គឺជាការពិនិត្យនិងតាមដានលើស្ថានភាពហិរញ្ញវត្ថុនិងប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ក្នុងគោលបំណងវាយតម្លៃលើសុវត្ថិភាពនិងភាពរឹងមាំរបស់គ្រឹះស្ថានក្នុងការអនុវត្តតាមច្បាប់បទប្បញ្ញត្តិ និងការណែនាំ ដែលបានដាក់ចេញដោយធនាគារជាតិនៃកម្ពុជា ។

សម្រាប់ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានអនុវត្តនិងបញ្ចប់ការត្រួតពិនិត្យដល់ទីកន្លែងចំពោះគ្រឹះស្ថានធនាគារចំនួន ២១ ធនាគារឯកទេសចំនួន ៤ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើចំនួន ៧ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៩ និងប្រតិបត្តិករឥណទានជនបទចំនួន ៥ ។

លទ្ធផលនៃការត្រួតពិនិត្យដល់ទីកន្លែងបានបង្ហាញថា គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុមានស្ថានភាពហិរញ្ញវត្ថុល្អប្រសើរ ព្រមទាំងអនុវត្តបានល្អតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន ។ ប៉ុន្តែ គ្រឹះស្ថានមួយចំនួននៅមានបញ្ហាប្រឈម ដូចជា ការអនុវត្តមិនបានពេញលេញតាមផែនការយុទ្ធសាស្ត្រ ការត្រួតពិនិត្យផ្ទៃក្នុង និងការអនុវត្តតាមគោលនយោបាយនិងនីតិវិធីរបស់គ្រឹះស្ថានសាមី ។ រាល់ចំណុចខ្វះខាតទាំងនេះ ធនាគារជាតិនៃកម្ពុជាបានផ្ដល់អនុសាសន៍ចំពោះគ្រឹះស្ថានសាមី ដើម្បីធ្វើការកែតម្រូវនិងមានវិធានការដោះស្រាយជាបន្ទាន់តាមស្ថានភាពជាក់ស្ដែង ។

### ៥.១.៣. ការត្រួតពិនិត្យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ នៅក្នុងឆ្នាំ២០១១ មានសមតុល្យឥណទានសរុប ចំនួន ២.៥៩១ ពាន់លានរៀល កើនឡើងចំនួន ៥០,៣% ធៀបនឹងឆ្នាំ២០១០ ដែលបានផ្ដល់ជូនអតិថិជនចំនួនជាង ១លាននាក់ ក្នុងនោះប្រមាណ ៨៣% ជាស្ត្រីរស់នៅតាមតំបន់ជនបទ ។

តាមរយៈការត្រួតពិនិត្យលើឯកសារ និងដល់ទីកន្លែងបានបង្ហាញថា គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុបានយកចិត្តទុកដាក់ជាចម្បងលើការពង្រឹងគុណភាពឥណទានរបស់ខ្លួន ដោយក្នុងនោះគ្រឹះស្ថានបានផ្ដោតជាសំខាន់

លើការជ្រើសរើសអតិថិជនដែលមិនជាប់ជំពាក់បំណុលនិងប្រវត្តិឥណទានល្អ ហើយមានការវិភាគវាយតម្លៃយ៉ាងម៉ត់ចត់លើលទ្ធភាពសងត្រឡប់ចំពោះមុខបររបស់អតិថិជននីមួយៗ ។ ជាមួយនឹងការខិតខំប្រឹងប្រែងទាំងនេះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទាំងអស់អាចរក្សាគុណភាពឥណទានរបស់ខ្លួនបានល្អប្រសើរ ហើយអនុបាតឥណទានមិនដំណើរការស្ថិតនៅក្នុងរង្វង់ ០,២២% ប៉ុណ្ណោះនៅដំណាច់ឆ្នាំ២០១១ ។ នេះជាលទ្ធផលគួរឲ្យកត់សម្គាល់ ទោះបីជាប្រទេសកម្ពុជាជួបប្រទះនឹងគ្រោះទឹកជំនន់នៅតាមតំបន់មួយចំនួនក្តី ។ ធនាគារជាតិនៃកម្ពុជានឹងបន្តការតាមដានយ៉ាងយកចិត្តទុកដាក់អំពីផលប៉ះពាល់ជាសក្តានុពលនៃគ្រោះទឹកជំនន់នេះជាមួយបណ្តាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពាក់ព័ន្ធ ។

ទន្ទឹមនឹងការរីកចម្រើនផ្នែកសេវាឥណទាន ប្រាក់បញ្ញើរបស់អតិថិជនជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើ មានការវិវឌ្ឍយ៉ាងឆាប់រហ័សគួរកត់សម្គាល់ដល់ប្រមាណ ៤៥៩ ពាន់លានរៀល ពោលគឺបានកើនឡើង ១៧៩,៩% ធៀបនឹងឆ្នាំ២០១០ ។ គិតត្រឹមដំណាច់ឆ្នាំ២០១១ គ្រឹះស្ថានដែលមានអាជ្ញាប័ណ្ណទទួលប្រាក់បញ្ញើពីសាធារណជនមានចំនួន ៧ រួមមាន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា អម្រឹត ហត្ថាកសិករ ប្រាសាក់ អង្គរមីក្រូហិរញ្ញវត្ថុ ក្រេឌីត និងវីសិនហ្វាន់ ។

បន្ថែមពីនេះ ដើម្បីរក្សាកំណើននៃវិស័យមីក្រូហិរញ្ញវត្ថុប្រកបដោយគុណភាព និងមានការជឿទុកចិត្តពីសាធារណជន ធនាគារជាតិនៃកម្ពុជាបានអនុវត្តយ៉ាងយកចិត្តទុកដាក់នូវការត្រួតពិនិត្យទាំងលើឯកសារ និងដល់ទីកន្លែងចំពោះគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ មិនតែប៉ុណ្ណោះ ការធ្វើបច្ចុប្បន្នកម្ម និងការដាក់ចេញបទបញ្ជានានា ក៏ត្រូវបានអនុវត្តផងដែរក្នុងគោលបំណងបង្កើតមូលដ្ឋានច្បាស់លាស់ដើម្បីសម្រួលដល់ការអនុវត្តប្រតិបត្តិការ និងការរីកចម្រើនអាជីវកម្មរបស់គ្រឹះស្ថាន ។ ដោយឡែក ប្រព័ន្ធព័ត៌មានគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (Microfinance Information System) ដែលជាប្រព័ន្ធរាយការណ៍អេឡិចត្រូនិក នឹងត្រូវដាក់ឲ្យអនុវត្តចំពោះគ្រប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅក្នុងដើមឆ្នាំ២០១២ ខាង មុខនេះ ។

### ៥.២. ការងារនីតិកម្ម

ជាមួយនឹងការរីកចម្រើននៃប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុទាំងទំហំនិងវិសាលភាពប្រតិបត្តិការ ធនាគារជាតិនៃកម្ពុជាបានពិនិត្យឡើងវិញ និងបានបញ្ចប់ការធ្វើបច្ចុប្បន្នកម្មច្បាប់និងបទប្បញ្ញត្តិមួយចំនួន និងបានចងក្រងកម្រងច្បាប់និងបទប្បញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីធ្វើឲ្យការងារត្រួតពិនិត្យកាន់តែប្រសើរឡើងថែមទៀត និងដើម្បីការពារប្រព័ន្ធធនាគារឲ្យកាន់តែមានភាពរឹងមាំ និងមានសុវត្ថិភាព ។

### ៥.៣. ការងារផ្តល់អាជ្ញាប័ណ្ណ

នៅឆ្នាំ២០១១ នេះ ធនាគារជាតិនៃកម្ពុជាបានសម្រេចផ្តល់អាជ្ញាប័ណ្ណជូនធនាគារពាណិជ្ជថ្មីចំនួន ២ អាជ្ញាប័ណ្ណគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ ចេញលិខិតយល់ព្រមជាគោលការណ៍ដល់ធនាគារពាណិជ្ជចំនួន ៣ ចេញលិខិតយល់ព្រមជាគោលការណ៍ដល់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ២ ។ ជាមួយគ្នានេះដែរ ធនាគារជាតិនៃកម្ពុជាបានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទថ្មីចំនួន ១ និងបន្តវិញ្ញាបនបត្រចុះបញ្ជីជាប្រតិបត្តិករឥណទានជនបទចំនួន ៥ ។ ទន្ទឹមនឹងនេះ ធនាគារជាតិនៃកម្ពុជាក៏បានសម្រេចចេញអាជ្ញាប័ណ្ណប្រកបអាជីវកម្មប្តូរប្រាក់ដល់ធនាគារពាណិជ្ជចំនួន ២២ តតិយភាគីចំនួន ៨ គ្រឹះស្ថាន

មីក្រូហិរញ្ញវត្ថុចំនួន ៣ និងលិខិតអនុញ្ញាតប្រកបអាជីវកម្មប្តូរប្រាក់ទៅអាជីវករចំនួន ៣៥ នៅរាជធានីភ្នំពេញ ។ ធនាគារជាតិនៃកម្ពុជាបានចេញលិខិតគោលការណ៍ដល់ក្រុមហ៊ុនក្រេឌីតប៊្យូរ៉ូកម្ពុជា ដែលបានស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដោយគ្រោងនឹងផ្តល់អាជ្ញាប័ណ្ណនាពេលឆាប់ៗខាងមុខនេះ ។

**៥.៤. ការងារអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា (ស.ហ.ក)**

អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា បានសហការជាមួយអគ្គនាយកដ្ឋានត្រួតពិនិត្យ បាននិងកំពុងចុះត្រួតពិនិត្យដល់ទីកន្លែងស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្មលើធនាគារចំនួន ១១ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុចំនួន ៣ ។

នៅថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១១ ស.ហ.ក បានចុះហត្ថលេខាលើឯកសារសហប្រតិបត្តិការ (Statement of Cooperation) ស្តីពីការផ្លាស់ប្តូរព័ត៌មានការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មជាមួយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុជប៉ុន ។

## ៦- ការផ្គត់ផ្គង់សេវាធនាគារកណ្តាល

### ៦.១- សេវាគ្រប់គ្រងគណនី

បច្ចុប្បន្ននេះ ធនាគារជាតិនៃកម្ពុជាគ្រប់គ្រងគណនីជារូបិយវត្ថុជាតិនិងជាដុល្លារអាមេរិកមានចំនួន ៩៦០ គណនី ។

#### ៦.១.១- សេវាផ្នែកគណនីចំពោះស្ថាប័នរដ្ឋ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រសិទ្ធភាពកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធនាគារជាតិនៃកម្ពុជាបានបើកគណនីជូនស្ថាប័នរដ្ឋ និងផ្តល់សេវាទូទាត់ដូចជា ការដកសាច់ប្រាក់ ការផ្ទេរប្រាក់ ការបើកប្រាក់បៀវត្សរ៍ជូនមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និងការចាត់សម្រួលសាច់ប្រាក់តាមរយៈការបង្វែរប្រាក់របស់រតនាគារជាតិ ។

ការបង់ពន្ធដារនិងពន្ធគយដោយផ្ទាល់នៅធនាគារជាតិនៃកម្ពុជា មានទំហំ ៣.៤០៥ ពាន់លានរៀល ។ ការទទួលការបង់ពន្ធ កាន់តែមានភាពមមាញឹកជាមួយនឹងការអនុវត្តការបង់ពន្ធលើអចលនទ្រព្យ ។

#### ៦.១.២- សេវាផ្នែកគណនីចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

គណនីដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុបានបើកនៅធនាគារជាតិនៃកម្ពុជា រួមមាន គណនីចរន្ត គណនីប្រាក់បញ្ញើមានកាលកំណត់ គណនីប្រាក់បញ្ញើធានាលើដើមទុន និងគណនីប្រាក់បម្រុងកាតព្វកិច្ច ។ សមតុល្យសរុបនៃប្រាក់បញ្ញើទាំងនោះមានចំនួន ២៥៧ ពាន់លានរៀល និង ១.៦៨៨ លានដុល្លារអាមេរិក ។

### ៦.២- សេវាផ្ទេរប្រាក់ក្នុងប្រទេស

+ ការផ្ទេរចូលមកទីស្នាក់ការកណ្តាល

-ជាប្រាក់រៀលមានចំនួន ៦២២ ពាន់លានរៀល

-ជាប្រាក់ដុល្លារអាមេរិកមានចំនួន ៥៩២ លានដុល្លារអាមេរិក

+ ការផ្ទេរចេញទៅសាខារាជធានី-ខេត្ត

-ជាប្រាក់រៀលមានចំនួន ១.២៧០ ពាន់លានរៀល

-ជាប្រាក់ដុល្លារអាមេរិកមានចំនួន ១៤៨ លានដុល្លារអាមេរិក ។

**៦.៣- សេវាផាត់ទាត់មូលប្បទានបត្រ**

ប្រតិបត្តិការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល និងជាប្រាក់ដុល្លារអាមេរិក ត្រូវបានអនុវត្ត ជារៀងរាល់ថ្ងៃធ្វើការ ។ ការទូទាត់តាមរយៈសភាផាត់ទាត់នេះ បានដំណើរការប្រកបដោយប្រសិទ្ធភាព ។

**៦.៣.១- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀល**

សភាផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់រៀលមានសមាជិកចំនួន ៣០ ក្នុងនោះ មានធនាគារពាណិជ្ជចំនួន ២៧ ធនាគារឯកទេសចំនួន ២ និងធនាគារជាតិនៃកម្ពុជា ។

ក្នុងឆ្នាំ២០១១ ការផាត់ទាត់បានដំណើរការចំនួន ២៣៦ ថ្ងៃ ហើយបានផាត់ទាត់មូលប្បទានបត្រចំនួន ៣៤.៧៤២ សន្លឹក ស្មើនឹង ១.៨២១ ពាន់លានរៀល ពោលគឺ កើន ៦% និង១២% រៀងគ្នា ធៀបនឹងឆ្នាំ២០១០ ។

**៦.៣.២- ការផាត់ទាត់មូលប្បទានបត្រចារឹកជាប្រាក់ដុល្លារអាមេរិក**

សមាជិកដែលចូលរួមផាត់ទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកមានចំនួន ៣៦ ក្នុងនោះមានធនាគារពាណិជ្ជចំនួន ៣១ ធនាគារឯកទេសចំនួន ៤ និងធនាគារជាតិនៃកម្ពុជា ។ ការផាត់ទាត់មូលប្បទានបត្រជាប្រាក់ដុល្លារអាមេរិកបានធ្វើឡើងចំនួន ២៣៦ថ្ងៃ មានមូលប្បទានបត្រចំនួន ៥៥៨.៨៩៤ សន្លឹក ស្មើនឹង ៩.៥៧៣ លានដុល្លារអាមេរិក។

ក្នុងឆ្នាំ២០១១ សកម្មភាពផាត់ទាត់ជាប្រាក់ដុល្លារអាមេរិកមានការកើនឡើងដូចការផាត់ទាត់ប្រាក់រៀលដែរ គឺចំនួនមូលប្បទានបត្រកើន ៧៣.៧០៥ សន្លឹក (១៥%) និងចំនួនទឹកប្រាក់កើនពី ៧.០០៨ លានដុល្លារអាមេរិក ទៅ ៩.៥៧៣ លានដុល្លារអាមេរិក (កើន ៣៧%) ។

**៦.៤- ការងារឥណទាន**

ក្នុងឆ្នាំ២០១១នេះ ធនាគារជាតិនៃកម្ពុជាបានផ្តល់ឥណទានចំពោះគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងប្រមូលបំណុលដែលដល់កាលទូទាត់សងដូចខាងក្រោម ៖

- សមតុល្យដើមឆ្នាំ ៣១ ពាន់លានរៀល
- ឥណទានដែលបានផ្តល់ ៦៥ ពាន់លានរៀល
- ឥណទានដែលបានទូទាត់សង ៧៧ ពាន់លានរៀល
- សមតុល្យចុងឆ្នាំ ១៩ ពាន់លានរៀល ។

**៦.៥- ការងារអនុវត្តហិរញ្ញប្បទាន និងកម្ចីរាជរដ្ឋាភិបាល**

**ក- ហិរញ្ញប្បទានឥតសំណងពីរាជរដ្ឋាភិបាលជប៉ុន**

**ក.១- ហិរញ្ញប្បទានឥតសំណងជាគម្រោង**

នៅក្នុងឆ្នាំ២០១១ រដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្នុងគម្រោងចំនួន ៥ គម្រោង

ដល់រាជរដ្ឋាភិបាលកម្ពុជាដែលមានទឹកប្រាក់សរុបចំនួន ៨.០៨៧ លានយ៉េន និងកំពុងប្រើប្រាស់មានដូចខាងក្រោម ៖

ទី១- គម្រោងការពារទឹកជំនន់ក្នុងទីក្រុងភ្នំពេញ (ជំហានទី៣) មានទឹកប្រាក់ចំនួន ៣.៧០០ លាន យ៉េន ។

ទី២- គម្រោងបំពាក់ឧបករណ៍សម្រាប់សកម្មភាពបោសសម្អាតមីនជំហានទី៦ មានទឹកប្រាក់ចំនួន ១.២៩៨ លានយ៉េន ។

ទី៣- គម្រោងជួសជុល និងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅទីរួមខេត្តនានា មានទឹកប្រាក់ចំនួន ២.៧៦០ លានយ៉េន ។

ទី៤- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស (Scholarship 1113) មានទឹកប្រាក់ចំនួន ២៧៣ លានយ៉េន ។

ទី៥- គម្រោងបំពាក់ឧបករណ៍អប់រំនៅដេប៉ាតឺម៉ង់ទេព្យកោសល្យធនធានរ៉ែ និងភូគព្ភសាស្ត្រនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានទឹកប្រាក់ចំនួន ៥៦ លានយ៉េន ។

ចំពោះគម្រោងដែលបានផ្តល់នាឆ្នាំកន្លងមក និងកំពុងតែអនុវត្តមិនទាន់ចប់មាន ៖

១- គម្រោងជួសជុលទ្វារទឹករលាំងជ្រៃខេត្តកំពង់ស្ពឺ មានទឹកប្រាក់ចំនួន ៨១៩ លានយ៉េន (ពុំទាន់បានប្រើប្រាស់នៅឡើយ)

២- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស SCHOLARSHIP0811 មានទឹកប្រាក់ចំនួន ៣៥៣ លានយ៉េន

៣- គម្រោងសាងសង់ស្ពានអ្នកលឿង (Bridge 2014) មានទឹកប្រាក់ចំនួន ១១.៩៤០ លានយ៉េន ។

រីឯគម្រោងដែលបានផ្តល់នាឆ្នាំកន្លងមក និងបានបញ្ចប់ក្នុងឆ្នាំ២០១១នេះ រួមមាន ៖

១- គម្រោងអភិវឌ្ឍន៍មន្ទីរពេទ្យខេត្តកំពង់ចាម

២- គម្រោងជីកអណ្តូងទឹកស្អាតស្រុកមេមត់ ខេត្តកំពង់ចាម

៣- គម្រោងសាងសង់សាលាបឋមសិក្សានៅរាជធានីភ្នំពេញ

៤- គម្រោងអាហារូបករណ៍អភិវឌ្ឍន៍ធនធានមនុស្ស SCHOLARSHIP 0710 និង SCHOLARSHIP 1012

៥- គម្រោងសាងសង់មជ្ឈមណ្ឌលអភិវឌ្ឍន៍វារីវប្បកម្មសមុទ្រ និង

៦- គម្រោងស្តារឡើងវិញកំណាត់ផ្លូវជាតិលេខ១ (ជំហានទី៣) ។

**ក.២- ហិរញ្ញប្បទានឥតសំណងក្រៅគម្រោង**

នៅក្នុងឆ្នាំ២០១១ រាជរដ្ឋាភិបាលជប៉ុនបានផ្តល់ហិរញ្ញប្បទានឥតសំណងក្រៅគម្រោងដល់រាជរដ្ឋាភិបាលកម្ពុជានូវទឹកប្រាក់ចំនួន ២៩០ លានយ៉េន ដល់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដើម្បីទ្រទ្រង់សន្តិសុខស្បៀងសម្រាប់កសិករក្រីក្រនៅតាមជនបទ ។

**ខ- កម្ចីសម្បទានរាជរដ្ឋាភិបាលជប៉ុន**

ចំពោះកម្ចីសម្បទានដែលបានផ្តល់កន្លងមក ហើយកំពុងតែអនុវត្តមិនទាន់ចប់មាន ៖

១- គម្រោងអភិវឌ្ឍន៍កំពង់ផែពហុបំណងរបស់កំពង់ផែក្រុងព្រះសីហនុ (L/A No.CP-P10) មាន

ទឹកប្រាក់ចំនួន ៧.១៧៦ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

២- គម្រោងផ្គត់ផ្គង់ទឹកស្អាតនៅនិរោធ (L/A No.CP-P9) មានទឹកប្រាក់ចំនួន ៣.៥១៣ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០១០)

៣- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (L/A No.CP-P8) មានទឹកប្រាក់ចំនួន ៣.៦៥១ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៨)

៤- គម្រោងអភិវឌ្ឍន៍ខ្សែបណ្តាញថាមពលអគ្គិសនីមហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P7) មានទឹកប្រាក់ចំនួន ២.៦៣២ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៧)

៥- គម្រោងអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (L/A No.CP-P6) មានទឹកប្រាក់ចំនួន ៣១៨ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៦)

៦- គម្រោងបង្កើតបណ្តាញទូរគមនាគមន៍មហាអនុតំបន់ទន្លេមេគង្គ (L/A No.CP-P5) មានទឹកប្រាក់ចំនួន ៣.០២៩ លានយ៉េន (ចុះហត្ថលេខាឆ្នាំ២០០៥) ។

## ៧- ការគ្រប់គ្រងចរាចរណ៍ធនបត្រ

ក្នុងឆ្នាំ២០១១ ចំណូលសាច់ប្រាក់រៀលតាមបេឡាប្រតិបត្តិការមានចំនួន ៦.៩០៣ ពាន់លានរៀល ធៀបនឹងឆ្នាំ២០១០ កើនឡើងចំនួន ៥% ក្នុងនោះ ចំណូលពីឃ្លាំងសម្រួលបោះផ្សាយកើនឡើង ៤០៨ ពាន់លានរៀល (១២,៧%) ចំណូលពន្ធដារ-ពន្ធគយកើនឡើង ៣២ ពាន់លានរៀល (៧,៧%) ប្រាក់បញ្ញើអគ្គិសនីកម្ពុជាកើនឡើង ២៧ ពាន់លានរៀល (៤,៧%) ចំណូលប្រាក់បញ្ញើអាជីវករកើនឡើង ៥៩១ ពាន់លានរៀល (១០០%) ចំណូលពីសាខាធនាគារជាតិនៃកម្ពុជាកើនឡើង ១៩ ពាន់លានរៀល (៥,៣%) និងចំណូលសាច់ប្រាក់ផ្សេងៗកើនឡើង ១១៤ ពាន់លានរៀល (៥២,៤%) ។ ក្រៅពីនេះ ក៏មានចំណូលមួយចំនួនថយចុះដែរ ដូចជា ប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុថយចុះ ៨២៨ ពាន់លានរៀល (៤៧,១%) និងចំណូលពីប្រាក់កក់ដេញថ្លៃនិងលក់ដុល្លារអាមេរិកថយចុះ ៣៦ ពាន់លានរៀល (១០០%) ។

រីឯចំណាយសាច់ប្រាក់តាមបេឡាប្រតិបត្តិការវិញ មានចំនួន ៦.៨៩១ ពាន់លានរៀល ធៀបនឹងឆ្នាំ២០១០ កើនឡើង ៤,៨% ក្នុងនោះ ចំណាយឱ្យរតនាគារជាតិកើនឡើង ២៤៩ ពាន់លានរៀល (១៥%) ចំណាយអាជីវករដកប្រាក់បញ្ញើកើនឡើង ៤១៨ ពាន់លានរៀល (១០០%) និងចំណាយផ្សេងៗ កើនឡើងចំនួន ១១៨ ពាន់លានរៀល (៤៧,៣% ) ។ ក្រៅពីនេះ ក៏មានចំណាយមួយចំនួនថយចុះដែរ ដូចជា ចំណាយបញ្ចេញទៅឃ្លាំងសម្រួលបោះផ្សាយថយចុះ ១៣៦ ពាន់លានរៀល (៤,៥%) ចំណាយលើការដកប្រាក់បញ្ញើគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុថយចុះ ២៦៧ ពាន់លានរៀល (៤៩,៧%) ចំណាយលើការដកប្រាក់បញ្ញើអគ្គិសនីកម្ពុជាថយចុះ ៨ ពាន់លានរៀល (១០០%) ចំណាយឲ្យសាខាធនាគារជាតិនៃកម្ពុជា ថយចុះ ៤២ ពាន់លានរៀល (៣,៩%) និងចំណាយដកប្រាក់កក់ដេញថ្លៃលក់ដុល្លារអាមេរិកថយចុះ ១៧ ពាន់លានរៀល (១០០%) ។

ក្នុងគ្រានេះដែរ សកម្មភាពប្រាក់ដុល្លារអាមេរិកបង់ចូលតាមបេឡាប្រតិបត្តិការសរុបមានចំនួន ២.៩២៩,៦ លានដុល្លារអាមេរិក កើនឡើង ១០៤,៥ លានដុល្លារអាមេរិក (៣,៧%) ហើយចំណាយតាមរយៈបេឡាប្រតិបត្តិការ មានចំនួន ២.៩២៩,៩ លានដុល្លារអាមេរិក កើនឡើង ១០៤,៦ លានដុល្លារអាមេរិក

(៣,៧%) បើធៀបនឹងឆ្នាំ២០១០ ។

ដើម្បីសម្រួលដល់ចរាចរណ៍ក្រដាសប្រាក់រៀល ធនាគារជាតិនៃកម្ពុជាបានបញ្ចេញក្រដាសប្រាក់ថ្មីដូរយកក្រដាសប្រាក់ចាស់ ទក់ រហែកចំនួន ៣១៣ ពាន់លានរៀល បើធៀបនឹងឆ្នាំ២០១០ កើនឡើង ៤០ ពាន់លានរៀល (១៤,៦%) ហើយបានធ្វើការកាត់កម្ទេច និងបំផ្លាញចោលក្រដាសប្រាក់ចាស់ ទក់ រហែកដោយម៉ាស៊ីនធម្មតាចំនួន ៨២៥ ពាន់លានរៀល កើនឡើង ១១ ពាន់លានរៀល (១,៤%) និងម៉ាស៊ីនស្វ័យប្រវត្តិ ចំនួន ៤៧៤ ពាន់លានរៀល កើនឡើងចំនួន ៤៣ ពាន់លានរៀល (១០%) ធៀបនឹងឆ្នាំ២០១០ ។

ចំពោះការងារគ្រប់គ្រងសាច់ប្រាក់ និងការងាររាំងខ្ទប់ក្រដាសប្រាក់ក្លែងក្លាយ ធនាគារជាតិនៃកម្ពុជាតែងតែតាមដាន និងសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចជាប្រចាំ ហើយបានដកហូតក្រដាសប្រាក់រៀលក្លែងក្លាយដែលជាប្រភេទថតចម្លងចំនួន ២៥៧សន្លឹក ថយចុះ ៣០៦សន្លឹក (៥៤%) និងក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយចំនួន ៤១២សន្លឹក ថយចុះ ៥៤១សន្លឹក (៥៦,៧%) បើធៀបនឹងឆ្នាំ២០១០ ព្រមទាំងបានសហការជាមួយធនាគារ UOB (United Overseas Bank Limited) រៀបចំធ្វើសិក្ខាសាលាស្តីពីការពិនិត្យក្រដាសប្រាក់ដុល្លារអាមេរិកក្លែងក្លាយចំនួន ៣លើក គឺនៅភ្នំពេញ ខេត្តបាត់ដំបង និងខេត្តសៀមរាប ។

**៨- ការអភិវឌ្ឍប្រព័ន្ធទូទាត់**

អនុលោមតាមយុទ្ធសាស្រ្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងអភិវឌ្ឍប្រព័ន្ធទូទាត់សងប្រាក់ដែលអាចទូទាត់ និងជាត់ទាត់ទាំងមូលប្បទានបត្រ និងឧបករណ៍ទូទាត់ផ្សេងៗទៀតជាលក្ខណៈមជ្ឈការ ដើម្បីសម្រួលដល់ការទូទាត់ឲ្យកាន់តែមានប្រសិទ្ធភាព និងសុវត្ថិភាព ស្របតាមការរីកចម្រើននៃវិស័យហិរញ្ញវត្ថុ និងសេដ្ឋកិច្ចជាតិ ។ ការបំពាក់ផ្នែកហាដវែ (Hardware) រួមទាំងមណ្ឌលរក្សាទិន្នន័យចម្បង និងមណ្ឌលសង្គ្រោះទិន្នន័យទី១ និងទី២ ត្រូវបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០១១ ។ រីឯការរៀបចំដំឡើងផ្នែកសូហ្វវែ (Software) ដំណាក់កាលទី១ នៅមណ្ឌលរក្សាទិន្នន័យចម្បង និងមណ្ឌលសង្គ្រោះទិន្នន័យទី១ និងទី២ ក៏ត្រូវបានបញ្ចប់ដែរ ។ បច្ចុប្បន្ន ក្រុមហ៊ុន CMA ដែលរៀបចំផ្នែកសូហ្វវែបាននិងកំពុងផ្តល់ការបណ្តុះបណ្តាលលើផ្នែកមុខងារ និងដំណើរការនៃប្រព័ន្ធ ។ ប្រព័ន្ធទូទាត់នេះ នឹងដាក់ឲ្យដំណើរការនៅក្នុងឆ្នាំ២០១២ ។

ក្រៅពីការងារអភិវឌ្ឍន៍ប្រព័ន្ធទូទាត់នេះ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងរៀបចំគម្រោងអភិវឌ្ឍន៍ប្រព័ន្ធ Shared Switch ។

ទន្ទឹមនឹងការអភិវឌ្ឍប្រព័ន្ធជាតិទូទាត់នេះ ធនាគារជាតិនៃកម្ពុជាបានសហការជាមួយសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) កំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ប្រព័ន្ធជាតិទូទាត់សងប្រាក់ (The Law on National Payments System) " ដើម្បីជាមូលដ្ឋានគតិយុត្តិក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធទូទាត់ ។

**៩- ការងារព័ត៌មានវិទ្យា**

ចំពោះការងារព័ត៌មានវិទ្យាប្រចាំឆ្នាំ២០១១ នេះ ធនាគារជាតិនៃកម្ពុជាបានផ្តោតសំខាន់លើគម្រោងធំៗពីរ ទីមួយគឺ ការដាក់ឲ្យដំណើរការប្រព័ន្ធធនាគារស្នូលនៅគ្រប់សាខាធនាគារជាតិនៃកម្ពុជាទូទាំងប្រទេស

និងទីពីរគឺ ការអនុវត្តគម្រោងប្រព័ន្ធទូទាត់ជាតិ ។ ចំពោះការដាក់ឲ្យដំណើរការប្រព័ន្ធធនាគារស្នូល ធនាគារជាតិនៃកម្ពុជាបានដំឡើងប្រព័ន្ធនេះនៅសាខាធនាគារជាតិនៃកម្ពុជាដែលនៅសេសសល់មិនទាន់បានដំឡើងទាំងអស់មានចំនួនដប់គឺ សាខាខេត្តកណ្តាល តាកែវ ព្រៃវែង កំពង់ស្ពឺ កំពត ក្រចេះ ស្ទឹងត្រែង កំពង់ធំ ពោធិ៍សាត់ និងរតនគិរី ។

សកម្មភាពការងារផ្សេងទៀតរួមមាន ការអភិវឌ្ឍប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់គាំទ្រការចេញផ្សាយមូលបត្ររបស់ធនាគារជាតិនៃកម្ពុជា ព្រមទាំងប្រព័ន្ធគ្រប់គ្រងនិងត្រួតពិនិត្យរបាយការណ៍របស់គ្រឹះស្ថានធនាគារ ។

## II- ការគ្រប់គ្រងផ្ទៃក្នុងធនាគារជាតិនៃកម្ពុជា

### ១- សកម្មភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជានាពេលបច្ចុប្បន្ន មានសមាសភាពដូចខាងក្រោម ៖

| | | |
|---|---|---|
| - ឯកឧត្តម ជា ចាន់តូ | ទេសាភិបាលធនាគារជាតិនៃកម្ពុជា | ជាប្រធាន |
| - លោកជំទាវ នាវ ច័ន្ទថាណា | ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា | ជាសមាជិក |
| - ឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន | តំណាងប្រមុខរាជរដ្ឋាភិបាល | ជាសមាជិក |
| - ឯកឧត្តម អ៊ីវ ថុង | តំណាងមជ្ឈដ្ឋានឧត្តមសិក្សា | ជាសមាជិក |
| - ឯកឧត្តម ជូ គឹមឡេង | តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| - លោក ឡាយ ម៉េងស៊ុន | តំណាងមជ្ឈដ្ឋានធ្វើសកម្មភាពសេដ្ឋកិច្ច | ជាសមាជិក |
| - លោកស្រី ម៉ៅ សុន | តំណាងបុគ្គលិកធនាគារជាតិនៃកម្ពុជា | ជាសមាជិក ។ |

ក្នុងឆ្នាំ២០១១ នេះ ក្រុមប្រឹក្សាភិបាលបានប្រជុំចំនួន ៦លើក ដើម្បីពិភាក្សា និងអនុម័តលើការងារមួយចំនួន ដូចខាងក្រោម ៖

១. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៤ នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ អំពី (១) របាយការណ៍ស្តីពីការកែសម្រួល និងបន្ថែមសមាសភាពក្រុមលេខាធិការក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា (២) ពិនិត្យនិងអនុម័តលើសេចក្តីព្រាងសេចក្តីសម្រេចស្តីពី ការបង្កើតគណៈកម្មការត្រួតពិនិត្យបញ្ជីគណនេយ្យធនាគារជាតិនៃកម្ពុជាសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១០ និង (៣) របាយការណ៍ស្តីពីការពង្រឹងការប្រើប្រាស់ប្រាក់រៀល

២. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៥ នាថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១១ ដើម្បីពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ស្តីពី ស្ថានភាពថវិកាធនាគារជាតិនៃកម្ពុជាឆ្នាំ២០១០ និងផែនការឆ្នាំ២០១១

៣. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៦ នាថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១១ ដើម្បីពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំឆមាសទី១ និងទិសដៅការងារឆមាសទី២ ឆ្នាំ២០១១ របស់ធនាគារជាតិនៃកម្ពុជា

៤. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៧ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១១ ដើម្បីពិនិត្យលើសមាសភាពសមាជិកក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា ក្នុងអាណត្តិថ្មី

៥. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី ៨៨ នាថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១១ ដើម្បីពិនិត្យនិងពិភាក្សាត្រៀមលក្ខណៈរៀបចំសេចក្តីព្រាងគោលនយោបាយវិនិយោគទុនបម្រុងអន្តរជាតិរបស់ធនាគារជាតិនៃកម្ពុជា

៦. កិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី៨៩ នាថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ ដើម្បីពិនិត្យនិងអនុម័តសេចក្តីព្រាងរបាយការណ៍ប្រចាំឆ្នាំ២០១១ និងទិសដៅការងារឆ្នាំ២០១២ របស់ធនាគារជាតិនៃកម្ពុជា ។

## ២- ការងារគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្ស

### ២.១- ស្ថិតិមន្ត្រីបុគ្គលិក

- ក្របខ័ណ្ឌធនាគារជាតិនៃកម្ពុជា (ទីស្នាក់ការកណ្តាល) នៅឆ្នាំ២០១១ មានចំនួន ៨៧៤រូប (ប្រុស ៤៩៦រូប ស្រី ៣៧៨រូប)
- ក្របខ័ណ្ឌសាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត មានចំនួន ៣៨៦រូប (ប្រុស ២២២រូប ស្រី ១៦៤រូប) ។

ដូច្នេះសរុបក្របខ័ណ្ឌមន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទូទាំងប្រទេសក្នុងឆ្នាំ២០១១ នេះមានចំនួន ១.២៦០រូប (ប្រុស ៧១៨រូប ស្រី ៥៤២រូប) បើប្រៀបធៀបជាមួយក្របខ័ណ្ឌក្នុងឆ្នាំ២០១០ ដែលមានចំនួន ១.២៥៥រូប (ប្រុស ៧១០រូប ស្រី ៥៤៥រូប) មានការប្រែប្រួលដូចតទៅ ៖

+ ទីស្នាក់ការកណ្តាល គឺកើនចំនួន ០៥រូប (ចូល ១៩រូប ចេញ ១៤រូប)
+ សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត នៅដដែល ( ចូល ២២រូប ចេញ ២២រូប) ។

### ២.២- ការងារបណ្តុះបណ្តាល

#### ក- ការងារបណ្តុះបណ្តាលក្នុងប្រទេស

ការអភិវឌ្ឍធនធានមនុស្សក្នុងឆ្នាំ២០១១នេះ ធនាគារជាតិនៃកម្ពុជាបានបណ្តុះបណ្តាលនិស្សិតថ្នាក់ប្រកាសនីយបត្រជាន់ខ្ពស់បច្ចេកទេសធនាគារ ដែលមាននិស្សិតសរុបចំនួន ៤៣៩រូប (ស្រី ២៦២រូប ប្រុស ១៧៧រូប) ក្នុងនោះដែរ និស្សិតក្នុងប្រព័ន្ធធនាគារមានចំនួន ១៩រូប (ស្រី ២រូប) ។ ជាមួយនេះដែរ ធនាគារជាតិនៃកម្ពុជាក៏បានបើកវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលាចំនួន២០លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ១.១១០ រូប) វគ្គសិក្សានៅសាលាភូមិន្ទរដ្ឋបាល (មន្ត្រីចូលរួមចំនួន០២រូប) វគ្គបណ្តុះបណ្តាលភាសាអង់គ្លេសនៅតាមបណ្តាសាខាធនាគារជាតិនៃកម្ពុជាចំនួន០២ (មន្ត្រីបុគ្គលិកសិក្សាចំនួន ២៧រូប)ភាសាអង់គ្លេសនៅ ACE (មន្ត្រីបុគ្គលិកសិក្សាចំនួន ១៩រូប) និងចូលរួមសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សេងៗ តាមការអញ្ជើញពីបណ្តាក្រសួង-ស្ថាប័ននានាចំនួន ១៧លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៤០រូប) និងត្រៀមរៀបចំប្រឡងឆ្លងចូលក្របខ័ណ្ឌមន្ត្រីបុគ្គលិក ។ ផ្នែកនេះក៏បានអញ្ជើញមន្ត្រីដែលបានត្រឡប់ពីធ្វើសិក្ខាសាលានៅបរទេស ដោយជ្រើសរើសយកប្រធានបទសំខាន់ៗមកឧទ្ទេសនាមឲ្យមន្ត្រីនៅកន្លែងបានចំនួន ០៤លើក (មន្ត្រី-បុគ្គលិកចូលរួមចំនួន ១២០រូប)។

#### ខ- ការងារបណ្តុះបណ្តាលក្រៅប្រទេស

ធនាគារជាតិនៃកម្ពុជាបានបន្តបង្កើនសមត្ថភាព និងអភិវឌ្ឍធនធានមនុស្សនៅក្រៅប្រទេសតាមរយៈសិក្ខាសាលាចំនួន ១១៧លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ១៧៥រូប) ទស្សនកិច្ចសិក្សាចំនួន ០៦លើក (មន្ត្រី

បុគ្គលិកចូលរួមចំនួន ៣៥រូប) វគ្គសិក្សារយៈពេលខ្លីចំនួន ២៣លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ៥០រូប) វគ្គសិក្សារយៈពេលវែងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ០៤លើក នៅប្រទេសញូហ្សេឡែន, អូស្ត្រាលី និងជប៉ុន (មន្ត្រីបុគ្គលិកចូលរួមចំនួន ០៥រូប) និងកិច្ចប្រជុំនានាចំនួន ៧៨លើក (មន្ត្រីបុគ្គលិកចូលរួមចំនួន ១៧៣រូប) តាមការអញ្ជើញនិងឧបត្ថម្ភរបស់ប្រទេសនិងស្ថាប័នអន្តរជាតិ ដូចជា មូលនិធិរូបិយវត្ថុអន្តរជាតិ ធនាគារពិភពលោក ធនាគារកណ្តាលម៉ាឡេស៊ី ធនាគារអភិវឌ្ឍន៍អាស៊ី រដ្ឋាភិបាលនៃប្រទេសឥណ្ឌា រដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន មជ្ឈមណ្ឌលSEACEN ធនាគារកណ្តាលសាធារណរដ្ឋឆែក ធនាគារកណ្តាលអាល្លឺម៉ង់ រដ្ឋាភិបាលអូស្ត្រាលី និងស្ថាប័នផ្សេងៗទៀត ។

## ៣- ការងារសវនកម្មផ្ទៃក្នុង និងអធិការកិច្ច

ក្នុងឆ្នាំ២០១១ នេះ ធនាគារជាតិនៃកម្ពុជាបានបំពេញការងារសវនកម្មផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព ដោយបានពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងលើការងារគ្រប់គ្រងសាច់ប្រាក់ និងលើលំហូរប្រតិបត្តិការក្នុងដំណើរការចុះកិច្ចបញ្ជិកាតាមប្រព័ន្ធធនាគារស្នូល (ប្រព័ន្ធ flexcube) និងសវនកម្មលើប្រព័ន្ធត្រួតពិនិត្យចេញ-ចូលជាក់ស្តែង និងប្រព័ន្ធត្រួតពិនិត្យចេញ-ចូលតាមប្រព័ន្ធកុំព្យូទ័រនៅនាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានបោះផ្សាយ និងឃ្លាំងបេឡា នាយកដ្ឋានគ្រប់គ្រងការប្តូរប្រាក់ ដែលក្នុងនោះផ្តោតសំខាន់លើប្រតិបត្តិការវិនិយោគទុនបម្រុង ការផ្ទេរប្រាក់ពីស្នាក់ការកណ្តាលទៅសាខា ការផ្ទេរប្រាក់ពីសាខាមកស្នាក់ការកណ្តាលវិញ ការបើក-បិទគណនី និងនៅតាមសាខាធនាគារជាតិនៃកម្ពុជា រួមមាន សាខាធនាគារជាតិនៃកម្ពុជារាជធានីភ្នំពេញ ខេត្តកំពង់ឆ្នាំង ខេត្តស្វាយរៀង ខេត្តបាត់ដំបង ខេត្តកំពត ខេត្តតាកែវ និងខេត្តក្រចេះ ។ របាយការណ៍សវនកម្មដែលរួមមានអនុសាសន៍មួយចំនួនផង ត្រូវបានដាក់ចេញដើម្បីធ្វើការកែលម្អ ចៀសវាងបាននូវហានិភ័យ ដើម្បីផ្តល់នូវសេវាកម្មដ៏ល្អប្រសើរ និងបង្កើនជំនឿទុកចិត្តដល់អតិថិជនចំពោះប្រព័ន្ធធនាគារស្នូល ។ ទន្ទឹមនឹងនោះ ការតាមដានការអនុវត្តតាមអនុសាសន៍ដែលបានដាក់ចុះ ក៏បានដំណើរការផងដែរនៅសាខាធនាគារជាតិនៃកម្ពុជា ខេត្តកំពង់ធំ ខេត្តព្រះសីហនុ និងខេត្តស្ទឹងត្រែង ។

ដោយឡែក ការងារអធិការកិច្ចត្រូវបានដំណើរការតាមរយៈការចុះឆ្មក់ត្រួតពិនិត្យដោយមិនជូនដំណឹងមុន លើសាខាធនាគារជាតិនៃកម្ពុជាចំនួន១០ ដែលការចុះត្រួតពិនិត្យបានផ្តោតជាសំខាន់លើការងារជានាសុវត្ថិភាព ឃ្លាំងប្រាក់ ការងារគ្រប់គ្រងសាច់ប្រាក់ និងការអនុវត្តរាល់សេចក្តីណែនាំរបស់នាយកដ្ឋានជំនាញដែលបានដាក់ចុះ ព្រមទាំងពង្រឹងគុណវុឌ្ឍិ និងវិន័យការងាររបស់មន្ត្រីបុគ្គលិកនៅតាមសាខាឲ្យបានកាន់តែប្រសើរ។

## ៤- ការងារគ្រប់គ្រងសាខាធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងប្រតិបត្តិការរបស់ខ្លួន ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចសហប្រតិបត្តិការតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាលជំហានទី២ ឲ្យកាន់តែមានប្រសិទ្ធភាព និងបានដាក់ឲ្យអនុវត្តកម្មវិធីប្រព័ន្ធធនាគារស្នូល បានគ្រប់សាខារាជធានី-ខេត្ត ព្រមទាំងបានបណ្តុះបណ្តាលនិងផ្គត់ផ្គង់ធនធានមនុស្សដើម្បីអនុវត្តភារកិច្ចនេះ ។ ដោយឡែក ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅបន្តការសាកល្បងជំហានទី១ និងជំហានទី២ លើការគ្រប់គ្រងចំណូល-ចំណាយថវិការដ្ឋដដែល ដោយបើកគណនីប្រតិបត្តិការចំណូល-ចំណាយថវិការដ្ឋនៅធនាគារអេស៊ីលីដា រួមមានរតនាគារខេត្តកំពង់ចាម កណ្តាល បន្ទាយមានជ័យ មណ្ឌលគិរី ស្ទឹងត្រែង កោះកុង ព្រះវិហារ ឧត្តរមានជ័យ

និងធនាគារកាណាឌីយ៉ា រួមមាន រតនាគារខេត្តសៀមរាប បាត់ដំបង និងព្រះសីហនុ ហើយរតនាគារខេត្តបាន បិទគណនីនៅសាខាធនាគារជាតិខេត្ត ។ ជំហានទី៣ ជាបណ្តើរៗ នឹងធ្វើនៅទីក្រុងភ្នំពេញ កំពង់ធំ កំពត ពោធិសាត់ ក្រចេះ និងរតនគិរី ។ ទន្ទឹមនេះដែរ ក៏មានរតនាគារខេត្តមួយចំនួនមិនទាន់បានផ្ទេរ ហើយនៅបន្តធ្វើប្រតិបត្តិការជាមួយសាខាធនាគារជាតិខេត្ត រួមមាន ព្រៃវែង កំពង់ធំ តាកែវ ស្វាយរៀង ពោធិ៍សាត់ កំពង់ឆ្នាំង កំពង់ស្ពឺ កំពត ក្រចេះ និងរតនគិរី ។

ក្នុងឆ្នាំ២០១១ នេះដែរ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានអនុញ្ញាតឲ្យសាលាស្រុក-ក្រុងទាំង ៣ រួមមាន ស្រុកពាមរក៍ (ខេត្តព្រៃវែង) ក្រុងស្ទឹងសែន (ខេត្តកំពង់ធំ) និងក្រុងក្រចេះ (ខេត្តក្រចេះ) បើកគណនីប្រាក់បញ្ញើនៅសាខាធនាគារជាតិនៃកម្ពុជា ។

## III- ទំនាក់ទំនងអន្តរជាតិ

### ១- ទំនាក់ទំនងពហុភាគី

#### ១.១- ទំនាក់ទំនងជាមួយមូលនិធិរូបិយវត្ថុអន្តរជាតិ

នៅក្នុងអំឡុងឆ្នាំ២០១១ នេះ មូលនិធិរូបិយវត្ថុអន្តរជាតិបានមកបំពេញទស្សនកិច្ចនៅធនាគារជាតិនៃកម្ពុជាចំនួន ២លើក ដែលលើកទី១ ជាបេសកកម្មជំនួយបច្ចេកទេសរបស់ Monetary and Capital Market Department រួមទាំងការបណ្តុះបណ្តាលសមត្ថភាពធនធានមនុស្សលើការគ្រប់គ្រងសន្ទនីយភាព និងការអភិវឌ្ឍទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ ជាដើម ។ ដោយឡែកបេសកកម្មលើកទី២ ជាបេសកកម្មប្រចាំគ្រានៃកិច្ចពិភាក្សាមាត្រាទី៤ យោងលក្ខន្តិកៈមូលនិធិរូបិយវត្ថុអន្តរជាតិ ។ ក្នុងឱកាសទស្សនកិច្ចគ្រានេះ បេសកកម្មមាត្រាទី៤ បានវាយតម្លៃវិជ្ជមានយ៉ាងខ្ពស់ចំពោះដំណើរការសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅប្រទេសកម្ពុជា ដោយបានកត់សម្គាល់ថា សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញលឿនជាងការរំពឹងទុក ប៉ុន្តែអត្រាកំណើនបានថយចុះមួយកម្រិតដោយសារគ្រោះទឹកជំនន់ ។ ជាលទ្ធផល អត្រាកំណើនឆ្នាំ២០១១ មាន ៥,៨% ខណៈសម្ពាធអតិផរណាបានកើនឡើងបន្តិច ។ ពាក់ព័ន្ធនឹងវិស័យធនាគារ បេសកកម្មបានអបអរសាទរចំពោះវឌ្ឍនភាពថ្មីៗជាច្រើន នៅពេលដែលវិស័យហិរញ្ញវត្ថុបន្តរក្សាស្ថិរភាពល្អ ។ បេសកកម្មក៏បានពិភាក្សាផងដែរ អំពីវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សំខាន់ៗរបស់កម្មវិធីវាយតម្លៃវិស័យហិរញ្ញវត្ថុ FSAP ព្រមទាំងអំពីបរិស្ថាននិងក្របខ័ណ្ឌនៃការអនុវត្តគោលនយោបាយសារពើពន្ធ និងរូបិយវត្ថុសម្រាប់រយៈកាលខ្លីនិងមធ្យម ។

ក្រៅពីបេសកកម្មទាំងពីរខាងលើ មូលនិធិរូបិយវត្ថុអន្តរជាតិបានជួយជ្រោមជ្រែងនិងបន្តផ្តល់ជំនាញការអចិន្ត្រៃយ៍សម្រាប់ការពង្រឹងផ្នែកត្រួតពិនិត្យធនាគារផងដែរ ។

#### ១.២- ទំនាក់ទំនងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី

ធនាគារអភិវឌ្ឍន៍អាស៊ីជាដៃគូដ៏សំខាន់មួយក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ។ សមិទ្ធផលចម្បងនៃសហប្រតិបត្តិការជាមួយធនាគារអភិវឌ្ឍន៍អាស៊ីនាឆ្នាំកន្លងមកនេះ គឺការធ្វើបច្ចុប្បន្នកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥ ទៅជាយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ២០១១-២០២០ តាមរយៈការផ្តល់ជំនួយបច្ចេកទេសនិងការទ្រទ្រង់ផ្សេងៗសម្រាប់រៀបចំឯកសារដ៏សំខាន់នេះ ។ ដោយយល់នូវសារៈសំខាន់ជាគន្លឹះនៃយុទ្ធសាស្ត្ររយៈកាលវែងនេះ រាជរដ្ឋាភិបាលបានអនុម័តលើខ្លឹមសារនៃឯកសារ កាល

ពីថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០១១ ។ ក្នុងនាមជាភ្នាក់ងារប្រតិបត្តិគម្រោង ធនាគារជាតិនៃកម្ពុជាបានផ្តួចផ្តើម ធ្វើបច្ចុប្បន្នកម្មឯកសារយុទ្ធសាស្ត្រនេះ សំដៅឆ្លើយតបទៅនឹងការវិវត្តដ៏លឿននៃស្ថានភាពសេដ្ឋកិច្ច/ហិរញ្ញវត្ថុ កម្ពុជាបច្ចុប្បន្ន និងតម្រូវការនាពេលអនាគត ។

ក្រៅពីនេះ ធនាគារជាតិនៃកម្ពុជាបានបន្តសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធនានាដើម្បីអនុវត្ត កំណែទម្រង់នៅក្នុងកម្មវិធីឥណទានអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុជំហានទី៣ ។ កម្មវិធីឥណទាននេះមានទឹកប្រាក់ សរុប ៤៥ លានដុល្លារអាមេរិក ហើយបានបែងចែកជា ៣ អនុកម្មវិធី សម្រាប់រយៈពេលបីឆ្នាំ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៣ ដែលអនុកម្មវិធីនីមួយៗមានទឹកប្រាក់ចំនួន ១៥ លានដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ១,៥% ក្នុងមួយឆ្នាំ ។ កាលពីថ្ងៃទី៤ ខែតុលា ឆ្នាំ២០១១ រាជរដ្ឋាភិបាលកម្ពុជាបានចុះហត្ថលេខាលើកំណត់ ហេតុនៃកិច្ចចរចាឥណទានសម្រាប់ការងារកំណែទម្រង់នៅក្នុងអនុកម្មវិធីទី១ ដែលក្របខ័ណ្ឌផែនការសកម្មភាព ចំនួន ២៥ ក្នុងនោះការងារពាក់ព័ន្ធនឹងធនាគារជាតិនៃកម្ពុជាមាន ១៣ ដែលផ្តោតលើកំណែទម្រង់ច្បាប់ ការ បង្កើតហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់ និងការពង្រឹងសមត្ថភាពត្រួតពិនិត្យ ។ អនុកម្មវិធីទី១ ត្រូវបានបំពេញ ចប់ជាស្ថាពរកាលពីខែវិច្ឆិកា ឆ្នាំ២០១១ នេះ ។

### ១.៣- ទំនាក់ទំនងជាមួយអាស៊ាន និងអាស៊ាន + ៣

ធនាគារជាតិនៃកម្ពុជាបន្តចូលរួមយ៉ាងសកម្មក្នុងកិច្ចសហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន ដើម្បីផ្លាស់ ប្តូរបទពិសោធន៍លើវិស័យសេដ្ឋកិច្ច/ហិរញ្ញវត្ថុ និងជំរុញវឌ្ឍនភាពក្នុងការអនុវត្តផែនការកំណែទម្រង់ផ្សេងៗ ស្របតាមការសម្រេចនិងការចង្អុលទិសរបស់ប្រមុខអាស៊ាន ។ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះ រៀបចំកិច្ចប្រជុំថ្នាក់ទេសាភិបាលរងអាស៊ានលើកទី៤ អំពីសមាហរណកម្មហិរញ្ញវត្ថុអាស៊ាន នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១១ នៅប្រទេសកម្ពុជាប្រកបដោយជោគជ័យ ។ ក្នុងឆ្នាំ២០១១នេះ គណៈប្រតិភូជាន់ខ្ពស់ នៃធនាគារជាតិនៃកម្ពុជាបានចូលរួមកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលអាស៊ានលើកទី៧ កិច្ចប្រជុំ ថ្នាក់ទេសាភិបាលរងធនាគារកណ្តាលនិងថ្នាក់អនុរដ្ឋមន្ត្រីហិរញ្ញវត្ថុអាស៊ានលើកទី១៩ និងកិច្ចប្រជុំពាក់ព័ន្ធ ផ្សេងៗទៀត ក្រោមក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការអាស៊ាន ព្រមទាំងអាស៊ាន+៣ (ចិន ជប៉ុន និងកូរ៉េ) ដែល បានរៀបចំឡើងនៅថ្ងៃទី៥-៨ ខែមេសា ឆ្នាំ២០១១ នៅប្រទេសឥណ្ឌូណេស៊ី ។ កិច្ចប្រជុំទាំងនេះ មាន គោលដៅជំរុញសមាហរណកម្មហិរញ្ញវត្ថុអាស៊ានឲ្យបានស៊ីជម្រៅ ដែលផ្តោតទៅលើវិស័យអាទិភាព៤ គឺ ការអភិវឌ្ឍទីផ្សារទុន សេរីភាវូបនីយកម្មគណនីដើមទុន សេរីភាវូបនីយកម្មសេវាហិរញ្ញវត្ថុ និងប្រព័ន្ធទូទាត់ និងផាត់ទាត់ ។

ដោយឡែក សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ ក៏មានវឌ្ឍនភាពគួរកត់សម្គាល់ផងដែរ ។ បច្ចុប្បន្ន នេះ សហប្រតិបត្តិការហិរញ្ញវត្ថុអាស៊ាន+៣ បាននិងកំពុងពិភាក្សាបន្ថែមមុខងារទប់ស្កាត់វិបត្តិ (Crisis Prevention Function) ទៅលើយន្តការពហុនីយកម្មគំនិតផ្តួចផ្តើមឈៀងម៉ៃ (CMIM) ដែលទើបនឹងបង្កើត ឡើងថ្មីៗ ។ ចំណែកការិយាល័យស្រាវជ្រាវម៉ាក្រូសេដ្ឋកិច្ចអាស៊ាន+៣ (AMRO) ក៏ត្រូវបានបង្កើតរួចហើយ កាលពីខែមេសា ឆ្នាំ២០១១ ដែលមានទីតាំងនៅប្រទេសសិង្ហបុរី និងមានតួនាទីជាចម្បង (i) សិក្សាវិភាគ តាមដាន វាយតម្លៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និង(ii) ជួយសម្រួលដល់ការអនុវត្តកិច្ចព្រមព្រៀង CMIM ។ កាលពីថ្ងៃទី៤ ខែវិច្ឆិកា ឆ្នាំ២០១១ លោកនាយក AMRO ព្រមទាំងក្រុមការងារបានមកបំពេញទស្សនកិច្ច

នៅកម្ពុជា ដើម្បីជូនព័ត៌មានពីវឌ្ឍនភាពការងាររបស់ការិយាល័យ AMRO ក៏ដូចជា ដើម្បីសិក្សាស្វែងយល់អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ការអនុវត្តគោលនយោបាយរូបិយវត្ថុ សារពើពន្ធ និងការអភិវឌ្ឍវិស័យធនាគារ/ហិរញ្ញវត្ថុនៅប្រទេសកម្ពុជាផងដែរ ។

លើសពីនេះ ប្រទេសអាស៊ាន+៣ បានបន្តពង្រឹងការអនុវត្តគំនិតផ្តួចផ្តើមទីផ្សារសញ្ញាប័ណ្ណអាស៊ាន (ABMI) សំដៅអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ប្រកបដោយប្រសិទ្ធភាព ។ ដើម្បីគាំទ្រការចេញផ្សាយសញ្ញាប័ណ្ណសាជីវកម្ម និងការអភិវឌ្ឍទីផ្សារសញ្ញាប័ណ្ណក្នុងតំបន់ឲ្យកាន់តែទូលំទូលាយ ប្រទេសអាស៊ានរួមជាមួយនឹងធនាគារអភិវឌ្ឍន៍អាស៊ីបានឯកភាពបង្កើតយន្តការធានាលើឥណទាននិងវិនិយោគ ដែលមានទឹកប្រាក់ចំនួន ៧០០ លានដុល្លារអាមេរិក ហើយដែលរំពឹងថានឹងចាប់ដំណើរការនៅឆ្នាំ ២០១២ ខាងមុខ ។ ទន្ទឹមនឹងនេះ វេទិកាទីផ្សារសញ្ញាប័ណ្ណអាស៊ាន+៣ ក៏ត្រូវបានបង្កើតឡើងផងដែរ ដើម្បីជួយដល់ការសម្របសម្រួលស្តង់ដារនិងបទប្បញ្ញត្តិទាក់ទងនឹងប្រតិបត្តិការសញ្ញាប័ណ្ណឆ្លងដែនក្នុងតំបន់ ។

**១.៤- ទំនាក់ទំនងជាមួយមជ្ឈមណ្ឌលធនាគារកណ្តាលអាស៊ីអាគ្នេយ៍ ( ស៊ាសិន - SEACEN )**

សមាជិកភាពរបស់ធនាគារជាតិនៃកម្ពុជានៅក្នុងមជ្ឈមណ្ឌលស៊ាសិន (SEACEN) បានផ្តល់ឱកាសជាច្រើនក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងការស្រាវជ្រាវលើវិស័យហិរញ្ញវត្ថុនិងធនាគារ ដើម្បីបង្កើនប្រសិទ្ធភាព និងជំនឿទុកចិត្តលើប្រតិបត្តិការធនាគារកណ្តាល ជាពិសេសក្នុងការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការពង្រឹងវិស័យធនាគារ ។

ក្នុងឆ្នាំនេះ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិស៊ាសិន (EXCO) លើកទី៩ ដើម្បីពិភាក្សាអំពីវឌ្ឍនភាពការងាររបស់ស៊ាសិនក្នុងឆ្នាំកន្លងទៅ និងលើកទិសដៅយុទ្ធសាស្ត្រសម្រាប់ឆ្នាំខាងមុខ ។ ក្នុងឱកាសនៃកិច្ចប្រជុំនេះ ក៏មានការរៀបចំផងដែរនូវសិក្ខាសាលា SEACEN-BIS ស្តីពី "ទំនាក់ទំនងម៉ាក្រូហិរញ្ញវត្ថុ: ស្ថិរភាពហិរញ្ញវត្ថុ និងកំណើនសេដ្ឋកិច្ច" ។

**១.៥- ទំនាក់ទំនងជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង ( ហ្វ្រង់កូហ្វូន - Francophone )**

បន្ទាប់ពីបានចូលជាសមាជិកនាឆ្នាំ១៩៩៣ មក កិច្ចសហប្រតិបត្តិការជាមួយសមាគមធនាគារកណ្តាលនៃបណ្តាប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) កាន់តែមានប្រសិទ្ធភាព និងជិតស្និទ្ធថែមទៀត ជាពិសេសចំពោះការផ្លាស់ប្តូរបទពិសោធន៍និងព័ត៌មានទៅវិញទៅមក និងការស្វែងរកជំនួយបច្ចេកទេសពីសំណាក់ធនាគារកណ្តាលជាដៃគូ ។

ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាសមាជិកហ្វ្រង់កូហ្វូន ធនាគារជាតិនៃកម្ពុជាមានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំប្រចាំឆ្នាំលើកទី១៨ ដែលបានប្រព្រឹត្តទៅពីថ្ងៃទី ១១-១៣ ខែឧសភា ឆ្នាំ២០១១ នៅខេត្តសៀមរាប ។

**២- ទំនាក់ទំនងទ្វេភាគី**

ទន្ទឹមនឹងជំនួយពហុភាគីដូចបានរៀបរាប់ខាងលើ ធនាគារជាតិនៃកម្ពុជាបានយកចិត្តទុកដាក់លើការកសាង និងពង្រឹងទំនាក់ទំនងទ្វេភាគីជាមួយបណ្តាធនាគារកណ្តាល និងស្ថាប័នអន្តរជាតិមួយចំនួនទៀត

ដើម្បីសម្រេចបានគោលដៅរួមគឺ ការពង្រឹងប្រព័ន្ធធនាគារជាទូទៅ នៅក្នុងបរិស្ថានសេដ្ឋកិច្ចពិភពលោកមួយដែលកាន់តែមានលក្ខណៈជាសកល ។

ជាក់ស្តែង ធនាគារជាតិនៃកម្ពុជាតែងបានទទួលជំនួយបច្ចេកទេសពីធនាគារកណ្តាលអាល្លឺម៉ង់លើផ្នែកបណ្តុះបណ្តាលធនធានមនុស្ស ដែលក្នុងឆ្នាំ២០១១ នេះ ធនាគារកណ្តាល អាល្លឺម៉ង់បានផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាចំនួនពីរលើក លើប្រធានបទពាក់ព័ន្ធនឹងការត្រួតពិនិត្យធនាគារ និងគោលនយោបាយរូបិយវត្ថុ ។

ក្នុងឱកាសទស្សនកិច្ចទ្វេភាគី កាលពីថ្ងៃទី២៥-២៨ ខែឧសភា ឆ្នាំ២០១១ នៅប្រទេសម៉ុងហ្គោលី ធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលម៉ុងហ្គោលីបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ក្នុងគោលបំណងពង្រឹងកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរបទពិសោធន៍ និងអភិវឌ្ឍន៍ធនធានមនុស្ស ។

ចំណែកកិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលថៃត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការផ្តល់ជំនួយផ្នែកបណ្តុះបណ្តាលធនធានមនុស្សជាបន្តបន្ទាប់ ។ ជាក់ស្តែង កាលពីថ្ងៃទី២៥-២៦ ខែឧសភា ឆ្នាំ២០១១ ធនាគារកណ្តាលថៃបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីប្រព័ន្ធផាត់ទាត់និងទូទាត់ និងវគ្គបណ្តុះបណ្តាលស្តីពីការត្រួតពិនិត្យដល់ទីកន្លែង កាលពីថ្ងៃទី២១-២៣ ខែធ្នូ ឆ្នាំ២០១២ នៅធនាគារជាតិនៃកម្ពុជា។

ដោយឡែក កាលពីខែកក្កដា នាឆ្នាំនេះ អាជ្ញាធររូបិយវត្ថុសិង្ហបុរីបានផ្តល់បទឧទ្ទេសនាមចំពោះមន្ត្រីធនាគារជាតិនៃកម្ពុជាក្នុងវគ្គសិក្ខាសាលាចំនួនពីរថ្ងៃ នៅធនាគារជាតិនៃកម្ពុជា លើប្រធានបទពាក់ព័ន្ធនឹងគោលនយោបាយរូបិយវត្ថុ និងការត្រួតពិនិត្យធនាគារ ។

លើសពីនេះទៀត ទំនាក់ទំនងជាមួយប្រទេសមីយ៉ាន់ម៉ាក៏ត្រូវបានពង្រឹង ។ នាថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១១ កន្លងមកនេះ ធនាគារជាតិនៃកម្ពុជាបានទទួលធ្វើបដិសណ្ឋារកិច្ចចំពោះប្រធានរដ្ឋសភាជាតិ និងគណៈប្រតិភូនៃប្រទេសមីយ៉ាន់ម៉ា ក្នុងដំណើរទស្សនកិច្ចជាផ្លូវការ ដែលបានឆ្លៀតឱកាសនោះស្វែងយល់ពីបទពិសោធន៍របស់ធនាគារជាតិនៃកម្ពុជាក្នុងការគ្រប់គ្រងប្រព័ន្ធធនាគារ ការអនុវត្តគោលនយោបាយរូបិយវត្ថុ និងការអភិវឌ្ឍវិស័យធនាគារនៅកម្ពុជា ។

កិច្ចសហប្រតិបត្តិការជាមួយធនាគារកណ្តាលឡាវត្រូវបានពង្រឹងថែមទៀត តាមរយៈកិច្ចប្រជុំទ្វេភាគីលើកទីពីររវាងធនាគារជាតិនៃកម្ពុជានិងធនាគារកណ្តាលឡាវ កាលពីថ្ងៃទី ៩-១៣ ខែធ្នូ ឆ្នាំ២០១១ នៅធនាគារជាតិនៃកម្ពុជា និងការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់អំពីកិច្ចសហប្រតិបត្តិការទូទៅ និងការត្រួតពិនិត្យធនាគារ ។

## សន្និដ្ឋាន

សូចនាករមួយចំនួននៅក្នុងអំឡុងពីរត្រីមាសចុងក្រោយនៃឆ្នាំ២០១១ បានបង្ហាញសញ្ញាថា ការស្តារឡើងវិញនៃសេដ្ឋកិច្ចពិភពលោកពីវិបត្តិសកលឆ្នាំ២០០៨-២០០៩ បានជួបប្រទះនឹងការលំបាកជាងការរំពឹងទុកពីមុន ជាពិសេស ចំពោះសេដ្ឋកិច្ចនៃប្រទេសអភិវឌ្ឍន៍ ដែលស្ថានភាពម៉ាក្រូសេដ្ឋកិច្ចកំពុងស្ថិតក្នុងសភាពផុយស្រួយ ទំនុកចិត្តនៃផ្នែកឯកជនមិនទាន់រឹងមាំ ហើយនិកម្មភាពនៅមានកម្រិតខ្ពស់ ។ ទន្ទឹមនោះ វិបត្តិបំណុលសាធារណៈនៅប្រទេសក្រិច ក៏មានទំនោរបង្កការឆ្លងរាលដាលដល់ប្រទេសមួយចំនួនទៀតក្នុងតំបន់អឺរ៉ុបផងដែរ ។ ដោយឡែកនៅតំបន់អាស៊ី ធនាគារកណ្តាលមួយចំនួនបានងាកមកអនុវត្តនយោបាយរូបិយវត្ថុបន្ធូរបន្ថយវិញ ដើម្បីជួយទ្រទ្រង់ដល់កំណើនសេដ្ឋកិច្ច ខណៈកម្រិតអតិផរណាបានចុះថមថយសន្សឹមៗ ។

ក្នុងស្ថានភាពដែលបរិស្ថានសេដ្ឋកិច្ចពិភពលោកមិនទាន់មានភាពរឹងមាំនឹងនរ ហើយសេដ្ឋកិច្ចតំបន់មានទំនោរបន្ថយល្បឿន ធនាគារជាតិនៃកម្ពុជារក្សាជំហរនយោបាយរូបិយវត្ថុទន់ភ្លន់និងសម្របសម្រួលតាមការចាំបាច់ ក្នុងគោលបំណងចូលរួមជំរុញការងើបឡើងវិញនៃសេដ្ឋកិច្ចប្រកបដោយចីរភាព ព្រមទាំងបង្កើនល្បឿនការអភិវឌ្ឍប្រទេសមួយកម្រិតថែមទៀត ។ ក្នុងអំឡុងពេលកន្លងមកនេះ ទោះបីថ្លៃទំនិញបានរងសម្ពាធខ្លះក្តី តែសម្ពាធនេះត្រូវបានទូទាត់មួយផ្នែកដោយស្ថិរភាពអត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិក ខណៈ ប្រតិបត្តិការជញ្ជីងទូទាត់មានភាពប្រសើរឡើងវិញ។ ប្រព័ន្ធធនាគារបន្តរក្សាស្ថិរភាពនិងកាន់តែមានលក្ខណៈស៊ីជម្រៅ ដែលបានទទួលការគាំទ្រជាបឋមពីការអនុវត្តការបង្កើនដើមទុនអប្បបរមារបស់គ្រឹះស្ថានធនាគារ ការពង្រឹងអភិបាលកិច្ចសាជីវកម្មនៅក្នុងប្រព័ន្ធ និងការលើកកម្ពស់បញ្ញត្តិកម្មប្រុងប្រយ័ត្នសម្រាប់គ្រឹះស្ថានធនាគារ ។

នាអនាគតខាងមុខ ផែនការសកម្មភាពចម្បងរបស់ធនាគារជាតិនៃកម្ពុជាត្រូវផ្តោតទៅលើការអនុវត្តកំណែទម្រង់តាមលំដាប់អាទិភាពដែលមានចែងនៅក្នុង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០១១-២០២០" ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័តជាផែនទីមគ្គុទ្ទេសក៍រយៈកាលវែងសម្រាប់ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជា ហើយដែលជាបច្ចុប្បន្នកម្មនៃ "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុឆ្នាំ ២០០៦-២០១៥" ។ ឯកសារយុទ្ធសាស្ត្រនេះត្រូវបានរៀបចំឡើងដោយផ្អែកលើលក្ខខណ្ឌនៃតម្រូវការក្នុងប្រទេសផង និងបទពិសោធន៍អន្តរជាតិផង ហើយក៏ត្រូវបានបន្ស៊ីឱ្យស៊ីសង្វាក់ជាមួយតម្រូវការធ្វើសមាហរណកម្មវិស័យហិរញ្ញវត្ថុតំបន់អាស៊ាន តាមការចង្អុលទិសនៃផែនទីមគ្គុទ្ទេសក៍បង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានផងដែរ ។

ជារួម ការងារកំណែទម្រង់ដំណាក់កាលជាបន្ទាប់នេះមានលក្ខណៈទូលំទូលាយ និងក្រសោបប្រព័ន្ធហិរញ្ញវត្ថុទាំងមូល រួមមាន ទីផ្សារទុន ទីផ្សាររូបិយវត្ថុនិងអន្តរធនាគារ ទីផ្សារប្តូរប្រាក់ ព្រមទាំងហេដ្ឋារចនាសម្ព័ន្ធទ្រទ្រង់ដ៏ចាំបាច់ផ្សេងៗនៃវិស័យហិរញ្ញវត្ថុ ដូចជា ការលើកកម្ពស់ក្របខ័ណ្ឌច្បាប់និងបទប្បញ្ញត្តិ ការពង្រឹងការប្រើប្រាស់រូបិយវត្ថុជាតិ និងការរៀបចំប្រព័ន្ធទូទាត់ប្រកបដោយប្រសិទ្ធភាពផងដែរ សំដៅធានាបម្រើការទូទាត់ប្រតិបត្តិការអាជីវកម្មដោយរលូននិងប្រកបដោយសុវត្ថិភាព ។

នាបច្ចុប្បន្ននេះ វិស័យហិរញ្ញវត្ថុកាន់តែមានថាមភាព ប្រទាក់ក្រឡា និងស្មុគស្មាញ ជាមួយនឹងការកើតមាន ឬទំនោរនៃការកើតមានប្រភេទគ្រឹះស្ថាន ឧបករណ៍ និងសេវាហិរញ្ញវត្ថុថ្មីៗ នៅក្នុងប្រទេសកម្ពុជា ។ ក្នុងបរិការណ៍នេះ ធនាគារជាតិនៃកម្ពុជាមានសេចក្តីត្រូវការចាំបាច់ក្នុងការពង្រឹងសមត្ថភាពបន្ថែមទៀតជាប្រចាំក្នុងការគ្រប់គ្រង និងត្រួតពិនិត្យប្រព័ន្ធធនាគារ ។

លើសពីនេះទៀត ស្ថិរភាពហិរញ្ញវត្ថុបានក្លាយជាសេចក្តីត្រូវការប្រកបដោយបច្ចុប្បន្នភាពមួយនៃសកលលោកទាំងមូល ហើយក៏ជាគោលដៅអាទិភាពជានិរន្តរ៍មួយសម្រាប់ប្រទេសកម្ពុជាផងដែរ ដែលរាជរដ្ឋាភិបាលកម្ពុជាតែងរំឭកឡើងជារឿយៗនៅលើវេទិកាសេដ្ឋកិច្ច/ហិរញ្ញវត្ថុនានា ហើយដែលមូលនិធិរូបិយវត្ថុអន្តរជាតិបានបញ្ជាក់ជាថ្មីក្នុងអំឡុងបេសកកម្មមាត្រាទី៤ ឆ្នាំនេះ ។ ដោយសារវត្តមាននៃទំនាក់ទំនង និងភាពប្រទាក់ក្រឡាគ្នានៃទីផ្សារហិរញ្ញវត្ថុ ព្រមទាំងលទ្ធភាពនិងហានិភ័យនៃការឆ្លងរាលដាលពីវិស័យមួយទៅវិស័យមួយទៀត ដូចវិបត្តិហិរញ្ញវត្ថុសកលថ្មីៗនេះជាឧទាហរណ៍ស្រាប់ អាជ្ញាធរត្រួតពិនិត្យនិងបញ្ញត្តិកម្មទាំងឡាយចាំបាច់ត្រូវពង្រឹងសហប្រតិបត្តិការជិតស្និទ្ធជាមួយគ្នា ដើម្បីឈានទៅសម្រេចបាននូវស្តង់ដារប្រុងប្រយ័ត្នជាអន្តរជាតិ ការមានក្របខ័ណ្ឌច្បាប់រឹងមាំនិងច្បាស់លាស់ និងយន្តការសមស្របសម្រាប់ត្រៀមរៀបចំនិងគ្រប់គ្រងឲ្យបានល្អប្រសើរចំពោះករណីកើតមានជាយថាហេតុនូវវិបត្តិហិរញ្ញវត្ថុ ។ ការបង្កើនកិច្ចសហប្រតិបត្តិការក៏ចាំបាច់ត្រូវធ្វើឡើងទាំងរវាងអាជ្ញាធរក្នុងស្រុក និងអាជ្ញាធរបរទេសផងដែរ ។

ក្នុងការជំរុញ ការអនុវត្តកំណែទម្រង់ប្រព័ន្ធធនាគារនឹងជួយពង្រឹងអន្តរការិយកម្មធនាគារមួយកម្រិតខ្ពស់ថែមទៀត ដែលនឹងជំរុញលំហូរឥណទានសម្រាប់ការវិនិយោគក្នុងវិស័យផលិតកម្មនិងកសិកម្ម បង្កើនប្រសិទ្ធភាពសេវាហិរញ្ញវត្ថុ កសាងប្រព័ន្ធទូទាត់ដើម្បីទ្រទ្រង់សកម្មភាពសេដ្ឋកិច្ច និងកាត់បន្ថយចំណាយចំពោះប្រតិបត្តិការហិរញ្ញវត្ថុ ។

